ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ : ០៩៩ រ.បក/អរប

ថ្ងៃ ២ ១៣កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ៣២ ខែ សីហា ឆ្នាំ២០២០

# របាយការណ៍
# ស្តីពី
# សកម្មភាព និងលទ្ធផលការងារប្រចាំខែកក្កដា និងទិសដៅបន្ត សម្រាប់ខែសីហា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានរដ្ឋបាល

អគ្គនាយកដ្ឋានរដ្ឋបាល គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំង១១ ចំណុះក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការឱ្យក្រសួង ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលក្នុងការបង្កើត ការចុះបញ្ជី និងគ្រប់គ្រងសកម្មភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តការងារតាមតួនាទី ភារកិច្ច ដោយសម្រេចលទ្ធផលបានដូចខាងក្រោម៖

## I-<u>សកម្មភាពការងារ និងលទ្ធផល</u>

### ១-ការងារលិខិតស្នាម និងឯកសារផ្សេងៗ

-បានទទួលលិខិត និងឯកសារ ដែលបញ្ជូនមកពីអគ្គលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះ ក្រសួងមហាផ្ទៃ សរុបចំនួន ៩៨១ច្បាប់ និងបានធ្វើការបែងចែកជូនទៅនាយកដ្ឋានចំណុះរួមមាន៖នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៤៩៥ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៥៣ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ២៦៦ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ៣១ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៣៧ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន៩៩ច្បាប់។

-បានទទួលលិខិតមកពីនាយកដ្ឋានជំនាញចំណុះអគ្គនាយកដ្ឋានរដ្ឋបាលចំនួន ៣៩៧ច្បាប់ ដែលក្នុងនោះមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ១១៧ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៣១ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១២៣ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ៣៧ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៣៣ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៥៦ច្បាប់ ដើម្បីដាក់ជូនអគ្គនាយកជ្រាបជារបាយការណ៍ និងពិនិត្យសម្រេច។

-បានចាត់ចែងបញ្ជូនឯកសារចំនួន ២៦៣ច្បាប់ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងជ្រាបជារបាយការណ៍និងពិនិត្យសម្រេច ដែលក្នុងនោះឯកសារមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៨៦ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ១៨ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៨៥ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ១២ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ២២ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៤០ច្បាប់។

-បានទទួលឯកសារចំនួន ១៦៧ច្បាប់ ដែលថ្នាក់ដឹកនាំក្រសួងមហាផ្ទៃពិនិត្យ សម្រេចរួច និងបញ្ជូនទៅនាយកដ្ឋានចំណុះ ដើម្បីចាត់ចែងបន្តរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន៤១ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន១៣ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៥៦ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ១០ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ១៩ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ២៨ច្បាប់។

**២-ការងារចេញលិខិតបង្គាប់ការ និង លិខិតបញ្ជាបេសកកម្ម**

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានចេញលិខិតបង្គាប់ការ និងលិខិតបញ្ជាបេសកកម្ម សរុបចំនួន ១៦០ច្បាប់(ក្នុងនោះលិខិតបង្គាប់ការ ៧៤ច្បាប់ និងលិខិតបញ្ជាបេសកកម្ម ៨៦ច្បាប់) ជូនថ្នាក់ដឹកនាំ និង មន្ត្រីចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះទៅបំពេញបេសកកម្មនៅតាមបណ្តាខេត្តនានា ។ ជាមួយគ្នានេះដែរអគ្គនាយកដ្ឋានរដ្ឋបាល ក៏បានចុះទិដ្ឋាការជូនមន្ត្រីរាជការមកពីបណ្តាខេត្ត ដែលមកបំពេញបេសកកម្មនៅក្រសួងមហាផ្ទៃផងដែរ។

**៣-ការងារប្រជុំ និងសិក្ខាសាលាផ្សេងៗ**

ក្នុងខែកក្កដាឆ្នាំ២០២០នេះ **អគ្គនាយកដ្ឋានរដ្ឋបាល** បានរៀបចំកិច្ចប្រជុំ និងចាត់មន្ត្រីចូលរួមកិច្ចប្រជុំ និងកម្មវិធីនានាដូចខាងក្រោម៖

-ចូលរួមជាមួយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងឱកាសអនុញ្ញាតឱ្យ៖

• ឯកឧត្តម **Christain Berger** ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ចូលជួបពិភាក្សាការងារ

• ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រាយការណ៍អំពីវឌ្ឍនភាពនៃការផ្ទេរសេវារដ្ឋបាលលើវិស័យសាធារណការ និងដឹកជញ្ជូន ទៅអនុវត្តនៅយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

-ចូលរួមជាមួយ **ឯកឧត្តម សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ ក្នុងឱកាសទទួលជួបប្រធានអង្គការមូលនិធិអាស៊ីប្រចាំកម្ពុជា ដើម្បីពិភាក្សាអំពីការសិក្សាថ្មី លើការវាយតម្លៃផលប៉ះពាល់មកលើអ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ក្នុងស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩។

▪ **ការប្រជុំ សិក្ខាសាលា៖**

-ដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយទីប្រឹក្សាគម្រោងលាភ នៅទីស្តីការក្រសួងមហាផ្ទៃ

-រៀបចំកិច្ចប្រជុំលើកទី៣ស្តីពីការគាំទ្ររបស់រដ្ឋបាលរាជធានី ខេត្តដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ លើការរៀបចំ និងអនុវត្តគម្រោងក្រុង ស្រុក ឃុំ សង្កាត់

-ចូលរួមកិច្ចប្រជុំជាន់ខ្ពស់រវាងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា ជាមួយតំណាងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ស្តីពីកម្មវិធីរួមគ្នាដើម្បីគាំទ្រជនទេសន្តរប្រវេសន៍ដែលវិលត្រឡប់ក្នុងស្ថានភាពនៃវិបត្តិជំងឺកូវីដ ១៩ និងផលប៉ះពាល់ នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយ ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង មក. នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំពិភាក្សាលើការធ្វើសមាហរណកម្មការរៀបចំថវិកាចរន្ត និងវិនិយោគនៅក្នុងក្របខ័ណ្ឌច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមកិច្ចប្រជុំលើកទី៦ ដើម្បីបន្តពិនិត្យពិភាក្សាសំណើ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិលក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផល ការងារចរាចរផ្លូវគោកប្រចាំឆមាសទី១ ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

-ចូលរួមកិច្ចប្រជុំពិនិត្យលើខ្លឹមសារសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការការងារបង្ការ ទប់ស្កាត់ និងប្រឆាំងបទល្មើសរវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងនគរបាលវៀតណាម នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំពិភាក្សា និងរៀបចំយន្តការលើករណីដែលនៅសេសសល់ពាក់ព័ន្ធនឹងការកាត់ឆ្វៀលដីជូនប្រជាពលរដ្ឋដែលបានកាន់កាប់និងអាស្រ័យផលជាក់ស្តែងយូរឆ្នាំមកហើយ ស្ថិតក្នុងតំបន់ការពារធម្មជាតិ និងគម្របព្រៃឈើ នៅទីស្តីការក្រសួងបរិស្ថាន

-ប្រជុំពិភាក្សាលើការរៀបចំប្រព័ន្ធទិន្នន័យគម្រោងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

-ចូលរួមកិច្ចប្រជុំស្តាប់របាយការណ៍ស្តីពីការបញ្ចប់ការងារតភ្ជាប់ទាញយកទិន្នន័យអត្តសញ្ញាណកម្ម និងប្រព័ន្ធផ្លាស់ប្តូរទិន្នន័យ CamDX សម្រាប់បម្រើដល់ការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

-ចូលរួមកិច្ចប្រជុំបច្ចេកទេសរវាងក្រុមការងារក្រសួងមហាផ្ទៃ និងក្រុមការងារក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីចុះសិក្សាស្រាវជ្រាវលើករណីការកាប់រាន ទន្ទ្រានកាន់កាប់ដីព្រៃខុសច្បាប់ក្នុងតំបន់ការពារធម្មជាតិ ស្ថិតក្នុងខេត្តមណ្ឌលគិរី នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំស្តីពី ដំណើរការនៃការរៀបចំការងារអង្កេតសហគ្រាសឧស្សាហកម្មកម្ពុជា ឆ្នាំ២០២០ នៅទីស្តីការក្រសួងផែនការ

-ចូលរួមកិច្ចប្រជុំពិភាក្សាអំពីការរៀបចំឯកសារបណ្តុះបណ្តាលនិងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធ ការគ្រប់គ្រងមុខងារអប់រំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីបទពិសោធន៍ និងបញ្ហាគោលការណ៍ក្នុងការប្រើអក្សរឡាតាំងសម្រាប់កត់សូរភាសាខ្មែរ នៅរាជបណ្ឌិត្យសភាកម្ពុជា

-ចូលរួមកិច្ចប្រជុំពិភាក្សាលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ០៣ឆ្នាំរំកិល (២០២១-២០២៣) និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២១ នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំលើកទី១ នៃអនុក្រុមការងារបច្ចេកទេសអន្តរក្រសួង ស្តីពីជីវសុវត្ថិភាព នៅទីស្តីការក្រសួងបរិស្ថាន

-ចូលរួមកិច្ចប្រជុំដើម្បីដោះស្រាយករណីក្រុមហ៊ុនវិនិយោគសត្តឃាតដ្ឋានជ្រូក ចំណតរថយន្តដឹកជញ្ជូនភ្ញៀវទេសចរណ៍ផ្លូវខ្លី និងចំណតរថយន្តក្រុងប៉ោយប៉ែត នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមកិច្ចប្រជុំដើម្បីត្រៀមចុះពិនិត្យ សិក្សា និងចងក្រងឯកសារទីតាំងដីក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះដែលប្រជាពលរដ្ឋបានប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែងក្នុងភូមិសាស្ត្រខេត្តកោះកុង នៅទីស្តីការក្រសួងបរិស្ថាន

-ចូលរួមកិច្ចប្រជុំស្តីពីក្រុមស្រាវជ្រាវមកពីវិទ្យាស្ថានសាគរចិនទី១ នៃក្រសួងធនធានធម្មជាតិចិនស្នើសុំស្រាវជ្រាវក្នុងតំបន់ដែនសមុទ្រកម្ពុជា នៅទីស្តីការក្រសួងបរិស្ថាន

-ចូលរួមកិច្ចប្រជុំពិភាក្សាបញ្ចប់ការរៀបចំសារាចរណែនាំស្តីពីនីតិវិធីកត់ត្រានិង ការអនុវត្តចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលសេវា ដែលផ្តល់នៅមន្ទីរជំនាញរាជធានី ខេត្ត

-ចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាកែសម្រួលបញ្ជីសូចនាករគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក) ២០១៦-២០៣០ ដែលរៀបចំដោយក្រសួងផែនការ

-ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើតារាងសកម្មភាព និងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រស្តីពីពិការភាពឆ្នាំ២០១៩-២០២៣

-ចូលរួមសិក្ខាសាលាផ្សព្វផ្សាយដំណើរការ នៃការអនុវត្តការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។

▪ កម្មវិធីផ្សេងៗ៖

-ចូលរួមជាអធិបតីក្នុងពិធីបិទវគ្គភាពជាអ្នកដឹកនាំសម្រាប់ថ្នាក់ដឹកនាំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅទីស្ដីការក្រសួងមហាផ្ទៃ

-ចូលរួមពិធីប្រកាសចូលកាន់មុខតំណែងរបស់អភិបាលរង នៃគណៈអភិបាលខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តកំពត និងខេត្តកែប

-ចូលរួមពិធីប្រគល់សម្ភារៈការពារជំងឺកូវីដ-១៩ ជូនអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ

-ចូលរួមកម្មវិធីបំផ្លាញសន្លឹកឆ្នោតដែលបានប្រើប្រាស់ឆ្នាំ២០១២-២០១៣-២០១៤ និងឆ្នាំ២០១៧

-ចូលរួមបេសកកម្មលើកទី២ ក្នុងការពិនិត្យតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាព និងរៀបចំផែនការយុទ្ធសាស្ត្រក្នុងការកំណត់ទិសដៅអនុវត្តបន្តគម្រោងលើកកម្ព ស់ជីវភាពប្រជាជនក្រីក្រ នៅខេត្តសៀមរាប។

## ៤-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

### ៤.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុង

#### ៤.១.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន (គ្មាន)

#### ៤.១.២-លិខិតបទដ្ឋានគតិយុត្តដែលកំពុងរៀបចំ

-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្ដីព្រាងអនុក្រឹត្យស្ដីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ និងការកែសម្រួលព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្ដីព្រាងអនុក្រឹត្យថ្មី ស្ដីពីការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-សេចក្ដីព្រាងប្រកាស ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់

-សេចក្ដីព្រាងសេចក្ដីណែនាំស្ដីពីនីតិវិធីនៃការផ្លាស់ប្ដូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្ដីព្រាងសេចក្ដីណែនាំស្ដីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្ដីព្រាងសេចក្ដីណែនាំស្ដីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្ដូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្ដីព្រាងសេចក្ដីណែនាំស្ដីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្ដីព្រាងសេចក្ដីណែនាំស្ដីពី ការអនុវត្តប្រកាសស្ដីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្ដីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្ដីព្រាងសេចក្ដីណែនាំ ស្ដីពីការវាយតម្លៃជ្រើសរើសរដ្ឋបាល ក្រុង ស្រុក ខណ្ឌឆ្នើម ក្នុងការផ្ដល់សេវារដ្ឋបាល

-សេចក្ដីព្រាងសេចក្ដីណែនាំ ស្ដីពីបែបបទ និងនីតិវិធីនៃការផ្ដល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់

-សេចក្ដីព្រាងសេចក្ដីណែនាំស្ដីពីការដាក់ឱ្យប្រើប្រាស់ទម្រង់ដីកានានាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្ដីព្រាងសេចក្ដីជូនដំណឹង ស្ដីពីការគ្រប់គ្រងមន្ត្រីរាជការនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌបន្ទាប់ពីការធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មី

-សេចក្ដីព្រាងគំរូកិច្ចសន្យា ស្ដីពីការផ្ដល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក

-សេចក្តីព្រាងសៀវភៅណែនាំស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសៀវភៅណែនាំស្តីពី"កិច្ចការរដ្ឋបាល"សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល)ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

**៤.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

**៤.២.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន**

-សេចក្តីណែនាំលេខ ០៣៦ សណន.សក.ដជទ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលក្នុងវិស័យដឹកជញ្ជូនផ្លូវទឹកនៅរដ្ឋបាលរាជធានី ខេត្ត

-សេចក្តីណែនាំអន្តរក្រសួងលេខ ០០១ MISTI/២០២០ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីសិប្បកម្មដែលមានដើមទុនសមមូលលើសពី៨០លានរៀល ដល់២០០លានរៀល និងគ្មានហានិភ័យ

-សេចក្តីណែនាំអន្តរក្រសួងលេខ ០០២ MISTI/២០២០ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**៤.២.២-លិខិតបទដ្ឋានគតិយុត្តកំពុងសហការរៀបចំ**

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងកែសម្រួលប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០២០-២០៣០។

**៥-ការងារបុគ្គលិក**

**៥.១-ការងារក្របខ័ណ្ឌ**

គិតត្រឹមខែកក្កដា ឆ្នាំ២០២០ ស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃសរុបមានចំនួន ៧.០៦៧រូប/ស្រី១.២៥០រូប (ក្នុងនោះក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ៩៩០រូប/ស្រី ២៤៥រូប ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិចំនួន ២.៩៦១រូប/ស្រី ៥៤១រូប ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ជាតិចំនួន ១.១៧៤រូប/ស្រី១៨៨រូប ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ក្រោមជាតិចំនួន ១.៩៤២រូប/ស្រី ២៧៦រូប) និងមន្ត្រីសុខាភិបាលថ្នាក់ក្រោមជាតិសរុបចំនួន ២០.១២៤រូប/ស្រី១០.៧១៤រូប បើប្រៀបធៀបទៅនឹង ខែមិថុនា ឆ្នាំ២០២០ ក្របខ័ណ្ឌថយចុះចំនួន ០៣រូប។ ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃក៏បានបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលពីក្របខ័ណ្ឌក្រសួងនានាចំនួន ០៣រូប/ស្រី០១រូប ក្របខ័ណ្ឌចេញចំនួន ០៦រូប (ក្នុងនោះផ្ទេរទៅក្នុងក្របខ័ណ្ឌក្រសួងនានាចំនួន ០៥រូប និងលុបឈ្មោះដោយមរណភាពចំនួន ០១រូប)។

**៥.២-ការងារគោលនយោបាយមន្ត្រីរាជការ**

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃឈប់សម្រាកលំហែមាតុភាពចំនួន ០៤រូប និងអនុញ្ញាតឱ្យចូលបម្រើការងារក្នុងអង្គភាពដើមវិញបន្ទាប់ពីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ០១រូប ( ក្នុងនោះមន្ត្រីរាជការស៊ីវិលចំនួន ០៣រូប និងមន្ត្រីពន្ធនាគារចំនួន ០២រូប)។ ជាមួយគ្នានេះផងដែរ ថ្នាក់ដឹកនាំក្រសួង ក៏បានផ្តល់គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រី

រាជការស៊ីវិលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួន ៥៦៦គ្រឿង ក្នុងនោះ៖ គ្រឿងឥស្សរិយយសជាតូបការចំនួន ០១គ្រឿង គ្រឿងឥស្សរិយយព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ចំនួន ៧១គ្រឿងរួមមាន(ថ្នាក់មហាសេរីវឌ្ឍន៍ ចំនួន ០៧គ្រឿង ថ្នាក់មហាសេនាចំនួន ០៩គ្រឿង ថ្នាក់ធិបឌិន្ទចំនួន ១៣គ្រឿង ថ្នាក់សេនាចំនួន ១៧គ្រឿង និងថ្នាក់អស្សឫទ្ធិចំនួន ២៥គ្រឿង) និងមេដាយការងារតាមលំដាប់ថ្នាក់ចំនួន ៤៩៤គ្រឿង រួមមាន៖(ថ្នាក់មាសចំនួន២២១គ្រឿង ថ្នាក់ប្រាក់ចំនួន ៨៩គ្រឿង ថ្នាក់សំរិទ្ធចំនួន ១៨៤គ្រឿង)។ ទន្ទឹមនោះក៏បានផ្តល់ប័ណ្ណសំគាល់ខ្លួនជូនប្រធានក្រុមប្រឹក្សាខេត្ត សមាជិកក្រុមប្រឹក្សាខេត្ត និងមន្ត្រីរាជការក្រសួងមហាផ្ទៃសរុបចំនួន ១១០រូប/ស្រី៣៤រូប (ក្នុងនោះសមាជិកក្រុមប្រឹក្សាខេត្តចំនួន ២៦រូប/ស្រី០៥រូប និងមន្ត្រីរាជការសរុបចំនួន ៨៤រូប/ស្រី២៩រូប)។

**៥.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

ក្នុងខែកក្កដា ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិលតាមមុខតំណែង ដែលកំពុងបម្រើការងារនៅគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃសរុបចំនួន ៩៩០រូប/ស្រី២៤៥រូប ស្មើនឹង២៤.៧៤% ដែលក្នុងនោះរួមមាន៖

-មន្ត្រីរាជការស៊ីវិលចំនួន ៩៧១រូប/ស្រី ២៤៣រូប ស្មើនឹង ២៥,០២% ក្នុងនោះរួមមាន (រដ្ឋលេខាធិការចំនួន ០៣រូប អនុរដ្ឋលេខាធិការចំនួន ០៣រូប/ស្រី ០១រូប អគ្គនាយកចំនួន ០១រូប អគ្គនាយករងចំនួន ២៨រូប/ស្រី០២រូប អគ្គលេខាធិការរងចំនួន ០៤រូប គណៈកម្មាធិការ គ.ជ.ប.ទចំនួន ០៣រូប (ក្នុងនោះសមាជិកគណៈកម្មាធិការចំនួន ០១រូប ប្រធានលេខាធិការដ្ឋានចំនួន ០១រូប អនុប្រធានលេខាធិការដ្ឋានចំនួន ០១រូប) ក្រុមប្រឹក្សានីតិកម្មចំនួន ០៧រូប/ស្រី០២រូប (ក្នុងនោះប្រធាន ០១រូប អនុប្រធាន ០៣រូប/ស្រី០១រូប សមាជិក ០៣រូប/ស្រី០១រូប) លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ចំនួន ១៧រូប/ស្រី០៦រូប អគ្គាធិការចំនួន ០១រូប អគ្គាធិការរងចំនួន ០៩រូប/ស្រី០១រូប ប្រធាននាយកដ្ឋានចំនួន ១១រូប/ស្រី០១រូប អនុប្រធាននាយកដ្ឋានចំនួន ១៧៣រូប/ស្រី៣៥រូប ប្រធានការិយាល័យ ចំនួន ៨៦រូប/ស្រី២០រូប អនុប្រធានការិយាល័យចំនួន ២៥៤រូប/ស្រី ៧០រូប និងមន្ត្រីចំនួន ៣៧០រូប/ស្រី១០៦រូប។

-មន្ត្រីដែលផ្ទេរភារកិច្ចពីថ្នាក់ក្រោមជាតិមកទីស្តីការក្រសួងចំនួន ១៩រូប/ស្រី០២រូប ស្មើនឹង១០,៥២%

-មន្ត្រីរាជការក្របខ័ណ្ឌដែលមានមុខតំណែងជាទីប្រឹក្សា និងជំនួយការចំនួន ៥៥៧រូប/ស្រី៥៦រូប ស្មើនឹង ១០,០៥% ។ ក្នុងខែកក្កដា ឆ្នាំ២០២០នេះដែរ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ បានពិនិត្យ សម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ផ្លាស់ប្តូរកន្លែងធ្វើការជូនមន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិសរុបចំនួន២៨រូប/ស្រី០២រូប។

**៥.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

គិតត្រឹមខែកក្កដា ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសសរុបចំនួន ៩.២៨៥រូប/ស្រី២.៦៧០រូប ដូចខាងក្រោម ៖

-គណៈអភិបាលរាជធានី ខេត្តសរុបចំនួន១៧៥រូប/ស្រី២៧រូប ស្មើនឹង១៥,៤២% ក្នុងនោះ(អភិបាលរាជធានី ខេត្តចំនួន ២៥រូប/ស្រី ០១រូប អភិបាលរងរាជធានី ខេត្តចំនួន ១៥០រូប/ ស្រី២៦រូប) គណៈអភិបាលក្រុង ស្រុក ខណ្ឌសរុបចំនួន៩៣៨រូប/ ស្រី១៩៨រូប ស្មើនឹង២១.១១% ក្នុងនោះ(អភិបាលក្រុង ស្រុក ខណ្ឌចំនួន ២០៣រូប/ស្រី០៧រូប អភិបាលរងក្រុង ស្រុក ខណ្ឌចំនួន ៧៣៥រូប/ស្រី ១៩១រូប)

-មន្ត្រីស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន ៦.៤៧២រូប/ស្រី២.១៤៤រូប ស្មើនឹង ៣៣.១៣% ក្នុងនោះ (សាលារាជធានី ខេត្តចំនួន ២.៨០៩រូប/ស្រី៩១០រូប ស្មើនឹង ៣២.៤០% សាលាក្រុង ស្រុក ខណ្ឌសរុបចំនួន ៣.៦៦៣រូប/ស្រី១.២៣៤រូប ស្មើនឹង ៣៣,៦៩%) ស្មៀនឃុំ សង្កាត់ចំនួន ១.៦៤៦រូប/ស្រី ៣០១រូប ស្មើនឹង១៨.២៩% និងប្រធានទីស្នាក់ការច្រកទ្វារព្រំដែនចំនួន ៥៤រូប ។ ទន្ទឹមនេះដែរ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃក៏បានពិនិត្យសម្រេចតែងតាំងមុខតំណែង ផ្ទេរភារកិច្ច បញ្ចប់មុខតំណែង អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុក ខណ្ឌ និងផ្លាស់ប្តូរភារកិច្ច និងតែងតាំងស្មៀនឃុំ សង្កាត់សរុបចំនួន ៤១រូប/ស្រី ០៣រូប (ដូចក្នុងឧបសម្ព័ន្ធ១ក-១ឃ)។

**៥.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ស្ថានភាព បច្ចុប្បន្នភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ទូទាំងប្រទេសមានដូចខាងក្រោម៖

-សមាសភាពក្រុមប្រឹក្សារាជធានី ខេត្តសរុបចំនួន ៥៥៩រូប/ស្រី៩៤រូប (ស្មើនឹង ១៦,៦៣%) ក្នុងនោះ (ប្រធានក្រុមប្រឹក្សារាជធានី ខេត្តចំនួន ២៥រូប សមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន ៥៣៤រូប/ស្រី ៩៤រូប)។

-សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសរុបចំនួន ៣.៥៥៥រូប/ស្រី៦២១រូប (ស្មើនឹង១៧,៥២%) ក្នុងនោះ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ២០៣រូប/ស្រី០៥រូប សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ៣.៣៥២រូប/ស្រី៦១៦រូប។

-សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន ១១.៥៧២រូប/ស្រី២.៣៨៣រូប(ស្មើនឹង២០.៥៧%)(ក្នុងនោះ មេឃុំចំនួន ១.៤០៥រូប/ស្រី ១១១រូប ចៅសង្កាត់ចំនួន ២៤១រូប/ស្រី ២៦រូប ជំទប់ទី១ ចំនួន ១.៤០៥រូប/ស្រី ២២៧រូប ជំទប់ទី២ចំនួន ១.៤០៥ រូប/ស្រី៣០៦រូប ចៅសង្កាត់រងទី១ចំនួន ២៤១រូប/ស្រី៦២រូប ចៅសង្កាត់រងទី២ចំនួន ២៤១រូប/ស្រី៥២រូប និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៦.៦៣៤រូប/ស្រី១.៥៩៩រូប)។ ក្នុងខែកក្កដា ឆ្នាំ ២០២០នេះ ក្រសួងមហាផ្ទៃបានផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ សរុបចំនួន២៧រូប/ស្រី០១រូប រួមមាន៖ សមាជិកក្រុមប្រឹក្សារាជធានី ចំនួន០១រូប (ដូចក្នុងឧបសម្ព័ន្ធ២ក)សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន០៥រូប(ដូចក្នុងឧបសម្ព័ន្ធ២ខ)និងសមាសភាព សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ចំនួន ២១រូប/ស្រី០១រូប (ដូចក្នុងឧបសម្ព័ន្ធ២គ)។

**៥.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

ក្នុងខែកក្កដា ឆ្នាំ២០២០ ស្ថានភាពប្រវត្តិរូបមន្ត្រីរាជការស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យសរុបចំនួន ១០.០៥៦រូប/ស្រី ២.៨៥០រូប(ក្នុងនោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ៨៧៨រូប/ស្រី ១៩៩រូប និងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិចំនួន ៩.១៧៨រូប/ស្រី២.៦៥១រូប)។

**៦-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៦.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានរៀបចំវគ្គបណ្តុះបណ្តាល និងចាត់បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល ដូចខាងក្រោម៖

-បានចាត់បញ្ជូនមន្ត្រីចំនួន ២០រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងផ្តោតលើលទ្ធផល (Result Based Management) នៅសណ្ឋាគារកំពតឌីយ៉ាម៉ង់

-បានរៀបចំវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ សម្រាប់ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន០១វគ្គ ដែលមានសិក្ខាកាមសរុបចំនួន ១២៦រូប/ស្រី០៦រូប នៅទីស្តីការក្រសួងមហាផ្ទៃ

-បានសហការជាមួយវ៉តធឺសេដ(WaterSHED)រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត ក្រុង ស្រុក ស្តីពីការអប់រំភាពជាអ្នកដឹកនាំដែលមានសិក្ខាកាមសរុបចំនួន ១៦៤រូប/ស្រី៤១រូប នៅខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។

**៦.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានរៀបចំសំណើសុំលិខិតឆ្លងដែនការទូតចំនួន ០១ច្បាប់ ជូនប្រធានក្រុមប្រឹក្សាខេត្តសៀមរាប ដើម្បីប្រើប្រាស់ក្នុងការបំពេញបេសកកម្មក្រៅប្រទេស។

**៦.៣-ការងារព័ត៌មាន និងផ្សព្វផ្សាយ**

ចំពោះការងារព័ត៌មាន និងផ្សព្វផ្សាយ អគ្គនាយកដ្ឋានរដ្ឋបាល បាននិងកំពុងរៀបចំសេចក្តីព្រាងព្រឹត្តិបត្រ ត្រីមាសិក និងវិសេសមាសិកលេខ ០៤ និងបន្តធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដោយបានបញ្ចូលអត្ថបទចំនួន ៥២ករណី និងបានផ្សព្វផ្សាយសេចក្តីជូនដំណឹង ៖

-អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមកម្មវិធីអាហារូបករណ៍ KOICA ទៅសិក្សានៅសកលវិទ្យាល័យជាតិសេអ៊ូល "Seoul National University (SNU)" សម្រាប់ឆ្នាំសិក្សា២០២០

-ការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់ក្រោយឧត្តមសិក្សា ថ្នាក់មធ្យមសិក្សាបច្ចេកទេស និងថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈទៅសិក្សានៅប្រទេសជប៉ុន ក្នុងឆ្នាំ២០២១។

## ៧-ការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

### ៧.១-ការគាំទ្របច្ចេកទេស និងអន្តរាគមន៍

ក្នុងកិច្ចគាំទ្របច្ចេកទេស និងអន្តរាគមន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាល បានរៀបចំលិខិតក្នុងនាមក្រសួងមហាផ្ទៃជម្រាបជូនទៅរដ្ឋបាលរាជធានី ខេត្ត និងរៀបចំលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាដូចខាងក្រោម៖

-សម្តេចតេជោនាយករដ្ឋមន្ត្រី ករណីធ្វើសេចក្តីរាយការណ៍អំពីការរកឃើញនាវាចំបាំង និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលបានលិចក្នុងទន្លេ ស្ថិតនៅភូមិវាល ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

-រដ្ឋបាលរាជធានីភ្នំពេញ ករណី៖

- ឈ្មោះ ហង់ យ៉យ, ហៃ គឹមហឿន, យិន ប៉ោលី និងឈ្មោះ អ៊ូ ហ៊្សរ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលរាជធានីភ្នំពេញឱ្យជួយដោះស្រាយវិវាទដីធ្លី និងផ្តល់ប័ណ្ណកម្មសិទ្ធិលើដីទំហំ ១.០៣៧.៥៣៩ម៉ែត្រការ៉េ របស់ប្រជាពលរដ្ឋចំនួន ១០៥គ្រួសារ ស្ថិតនៅភូមិចុងកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-រដ្ឋបាលខេត្តកែប ករណីគណនីឈ្មោះ KS Prom ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តកែបឱ្យធ្វើការវាស់វែងដីម្តងទៀតឱ្យបានច្បាស់លាស់ ដើម្បីទទួលបានលទ្ធផលត្រឹមត្រូវ ព្រោះអ្នកជិតខាងកំពុងប្រើប្រាស់អំណាចលួចយកដីរបស់គាត់ ស្ថិតនៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។

-រដ្ឋបាលខេត្តរតនគិរី ករណីការដាក់ចេញប្រកាសស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តរតនគិរី

-រដ្ឋបាលខេត្តស្ទឹងត្រែង ករណីការធ្វើសេចក្តីរាយការណ៍អំពីការចុះទប់ស្កាត់ការកាប់ទន្ទ្រានដីព្រៃឈើយកធ្វើជាកម្មសិទ្ធិត្រង់ចំណុចដៃអូរសេរ ភូមិបានបុង ឃុំភ្លុក ស្រុកសេសាន ខេត្តស្ទឹងត្រែង

-រដ្ឋបាលខេត្តកំពង់ធំ ករណីឈ្មោះ ជួប សម្បត្តិ, រស់ ប្រុស, យ៉េន ស៊ីនឿន និងឈ្មោះ ជួន រី តំណាងប្រជាពលរដ្ឋចំនួន១១៥គ្រួសារ ស្នើសុំអន្តរាគមន៍ដោះស្រាយវិវាទដីធ្លីជាមួយក្រុមហ៊ុន អាន សុភី,ក្រុមហ៊ុនហ្គោល ដេន,ក្រុមហ៊ុន នុភាព សុភី និងក្រុមហ៊ុន ខេមបូឌា ហ្វាម៉ រ និងសុំចេញប័ណ្ណកម្មសិទ្ធិ ស្ថិតនៅតំបន់អូរតាម៉ាន់ តំបន់ចង្អូរធ្លក និងតំបន់អូរតាចក់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ

-រដ្ឋបាលខេត្តកោះកុង ករណីតំណាងប្រជាពលរដ្ឋ ៧៤៣គ្រួសារ ស្នើសុំជួយជំរុញ និងពន្លឿនការដោះស្រាយជម្លោះដីធ្លីរវាងប្រជាពលរដ្ឋចំនួន ៧៤៣គ្រួសារ ជាមួយក្រុមហ៊ុន កោះកុងស៊ូហ្គើ និងកោះកុង ផ្លេនថេសិនអ៊ីនដាស្ទ្រី ខមផេនី លីមិតធីត របស់លោកឧកញ៉ា លី យ៉ុងផាត់ នៅក្នុងទឹកដីស្រុកបូទុមសាគរ ស្រុកថ្មបាំង និងស្រុកស្រែអំបិល។

-រដ្ឋបាលខេត្តព្រះសីហនុ ករណី៖

- ប្រជាពលរដ្ឋចំនួន០៤រូប ស្នើសុំអន្តរាគមន៍ចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែងកំណត់ព្រំដី និងកាត់ឆ្វៀលដីទំហំ ៣៤ហិចតា ៥៦អា ចេញពីតំបន់គម្របព្រៃឈើ និងដែនសមត្ថកិច្ចបរិស្ថាន ស្ថិតនៅភូមិ ០៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
- ប្រជាពលរដ្ឋចំនួន០៦រូប ស្នើសុំអន្តរាគមន៍ចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែងកំណត់ព្រំដី និងកាត់ឆ្វៀលដីទំហំ ៦០ហិចតា ចេញពីតំបន់សម្បទានសង្គមកិច្ច តំបន់គម្របព្រៃឈើ និងដែនសមត្ថកិច្ចបរិស្ថាន ស្ថិតនៅភូមិ០១ ឃុំទំនប់រលក (អតីតមណ្ឌល០១សង្កាត់អូរត្រេះ) ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

-រដ្ឋបាលខេត្តពោធិ៍សាត់ ករណីសំណើសុំបំភ្លឺករណីមានអន្តរាគមន៍ឱ្យដោះលែងជនល្មើសដែលបានឈូសឆាយចាប់យកដីព្រៃទំហំ២៤១ ហិកតា ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិជួរភ្នំក្រវាញ។

-រដ្ឋបាលខេត្តសៀមរាប ករណីសំណើសុំកំណត់ព្រំប្រទល់រដ្ឋបាលរវាងរដ្ឋបាលខេត្តសៀមរាប និងខេត្តឧត្តរមានជ័យពាក់ព័ន្ធនឹងវិវាទដីធ្លីរបស់ប្រជាពលរដ្ឋ ស្ថិតនៅចំណុចជប់ម្លូរ ឃុំវ៉ារិន ស្រុកវ៉ារិន ខេត្តសៀមរាប។

-រដ្ឋបាលខេត្តកំពង់ចាម ករណីស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ធ្វើសេចក្តីរាយការណ៍ឆ្លើយតបនឹងបណ្តឹងរបស់ឈ្មោះសែម បូរ៉ា ភេទប្រុសអាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបរជាអគ្គនាយកទូរទស្សន៍អនឡាញ ធី អ៊ិន អឹម (TNMTVonline) មានទីលំនៅផ្ទះលេខ ១១A សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ

-រដ្ឋបាលខេត្តស្វាយរៀង ករណីបណ្តឹងរបស់តំណាងប្រជាពលរដ្ឋចំនួន ៤៤០គ្រួសារ ស្នើសុំអន្តរាគមន៍ចាត់មន្ត្រីជំនាញចុះអង្កេតវាស់វែង និងធ្វើប័ណ្ណកម្មសិទ្ធិដីទំហំ ៦៧០ហិកតា ស្ថិតនៅឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង។

-រដ្ឋបាលខេត្តកំពង់ស្ពឺ៖

• បានធ្វើលិខិតឆ្លើយតបទៅលោកស្រី ឆាយ វិនិតា ករណីស្នើសុំបដិសេធលិខិតលេខ ២១២/២០ បេក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ ស្តីពីរបាយការណ៍នៃការចុះស្រាវជ្រាវករណីបណ្តឹងរបស់ឈ្មោះ ឆាយ វិនិតា ដែលបានប្តឹងអាជ្ញាធរឃុំក្រាំងដីវ៉ាយ អាជ្ញាធរស្រុកភ្នំស្រួច ថាបានឃុបឃិតគ្នាជាមួយឈ្មួញឈូសឆាយដីកសិកម្មចំនួន ០២កន្លែងទំហំ ៥១៩,៥៤ហិកតា ស្ថិតនៅភូមិដក់ពរ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

• ករណីឈ្មោះ ពុធ ម៉េងគួង, ពុត គង់ និងឈ្មោះ កាង ឈុនឡុន ស្នើសុំជួយរកយុត្តិធម៌ និងដោះស្រាយករណីឈ្មោះ ហុក ម៉ារ៉ាឌី មិនឱ្យធ្វើអាជីវកម្មលើទីតាំងដីដែលមានអាជ្ញាប័ណ្ណរួចហើយ ស្ថិតនៅភូមិសំពៅ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណីឈ្មោះ រិទ្ធ សុគន្ធា ចោទប្រកាន់ឈ្មោះ វ៉ែន រើក និងឈ្មោះ អេង សំអឿន អំពីការក្លែងបន្លំឯកសារលោកយកដីស្ថិតនៅភូមិខ្លាកូនចាស់ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តតាកែវ ករណី៖

• ឈ្មោះ ឥន្ទ គា, ឡុក ស្រីពៅ, ខាត់ សកំដា, តាំង សៀន, ស៊ុំ សុលី, អៀម នាង, អ៊ូច ប៊ុណ្ណា, ហាក់ ហេង, ថាវ សុគន្ធ, ថុក គន្ធា, សែត ខុន និងឈ្មោះ ជួង សុខា ស្នើសុំអន្តរាគមន៍មករដ្ឋបាលខេត្តតាកែវ បង្កើតគណៈកម្មការចម្រុះថ្នាក់ខេត្ត ចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ និងអង្កេតដីជាក់ស្តែងទំហំ៣.២៣៣ម៉ែត្រការ៉េ ស្ថិតនៅភូមិ២ សង្កាត់កោក្លូង ក្រុងដូនកែវ ខេត្តតាកែវ

• ឈ្មោះ ស៊ិន ផានី ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តតាកែវ ឱ្យជួយដោះស្រាយវិវាទព្រំដីរវាងដីផ្សារល្វេថ្មី និងដីរបស់លោកស្រី ហាក់ ផុន ស្ថិតនៅភូមិត្រពាំងលើក ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ។

-រដ្ឋបាលខេត្តកំពត ករណី ៖

• ឈ្មោះ មាស សេរី និងឈ្មោះ សេង ធី ស្នើសុំអន្តរាគមន៍រកយុត្តិធម៌លើបញ្ហាដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានកាប់បំផ្លាញដើមអាកាស្យាចំនួន ៧.៣០៣ដើម លើទីតាំងដីដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ ស្ថិតនៅភូមិចង្អៀងខាងកើត ឃុំទទុង ស្រុកដងទង់ ខេត្តកំពត

• តំណាងប្រជាពលរដ្ឋចំនួន ២៤១គ្រួសារ ស្នើសុំជួយអន្តរាគមន៍ដោះស្រាយដីបឹងស្ពានធំ ស្ថិតនៅភូមិ-ដំណាក់ក្រឡាញ់ខាងកើត ឃុំភ្នំប្រាសាទ ស្រុកកំពង់ត្រាច ខេត្តកំពត។

-បានចាត់ចែងធ្វើការដោះស្រាយចំពោះមតិយោបល់ ឬសំណូមពររបស់មហាជន ដែលបានផ្ញើចូលក្នុងគេហទំព័រហ្វេសប៊ុកសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ( ដូចក្នុងឧបសម្ព័ន្ធ ៣ )។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាល បានអនុវត្តកិច្ចការមួយចំនួន ដើម្បីគាំទ្រដល់ការបំពេញតួនាទី ភារកិច្ចដល់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

-បានចុះពិនិត្យ សិក្សា ស្រាវជ្រាវលើករណីបណ្តឹងលើទំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋចំនួន ១៤២គ្រួសារ ដែលរស់នៅភូមិអូរតាម៉េង ចំណុចជប់ត្រកួន និងចំណុចអូរអំបិល ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

-បានចុះសិក្សា និងប្រមូលធាតុចូល ដើម្បីរៀបចំប្រព័ន្ធរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធតាមដានត្រួតពិនិត្យវាយតម្លៃកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត ចាប់ពីថ្ងៃទី១-១០ខែកក្កដា ឆ្នាំ២០២០ នៅរដ្ឋបាលរាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តពោធិ៍សាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅមួយចំនួន។

-បានរៀបចំសំណើ សុំអនុញ្ញាតជាគោលការណ៍ ចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ ក្នុងកាលបរិច្ឆេទ២០២០។

-បានរៀបចំលិខិតជម្រាបរដ្ឋបាលរាជធានី ខេត្ត ស្ដីពីការពង្រឹងការអនុវត្តវិធានការការពារសុវត្ថិភាពសង្គមតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ដើម្បីកាត់បន្ថយហានិភ័យនៃការរីករាលដាលជំងឺកូវីដ ១៩ក្នុងអំឡុងពេល នៃថ្ងៃឈប់សម្រាក។

-មេធាវីឈ្មោះ ដារ៉ា សុបញ្ញា តំណាងដោយអាណត្តិឱ្យលោកស្រី ស ស៊ន់ ស្នើសុំអន្តរាគមន៍ជួយដោះស្រាយបញ្ហាដីធ្លីទំហំ ១៩២.៥៧៣,៧ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិដូង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

**៧.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន ០១ ខេត្ត២៤ ក្រុង២៧ ស្រុក១៦២ ខណ្ឌ១៤ ឃុំ១.៤០៥ សង្កាត់២៤១ និងភូមិចំនួន ១៤.៣៩៦។ ក្នុងខែកក្កដាឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានសម្រេចឱ្យបង្កើតភូមិចំនួន០២ គឺភូមិព្រៃល្វាត្បូងដោយបំបែកចេញពីភូមិព្រៃល្វាកើត នៃឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ និងភូមិជំនីក នៃឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។

**៧.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

ក្រសួងមហាផ្ទៃបានលើកសំណើជូនរាជរដ្ឋាភិបាលកម្ពុជា ករណីស្នើសុំគោរមងារជាឧកញ៉ា ចំនួន០៣រូប មេដាយព្រះរាជាណាចក្រកម្ពុជាចំនួន ៤៦គ្រឿង(ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៦គ្រឿង ថ្នាក់មហាសេនាចំនួន ០៨គ្រឿង ថ្នាក់ធិបឌិន្ទចំនួន ១៤គ្រឿង និងថ្នាក់សេនាចំនួន ១៨គ្រឿង) មេដាយមុនីសារាភ័ណ្ឌចំនួន ២៤គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៧គ្រឿង ថ្នាក់មហាសេនាចំនួន ១៦គ្រឿង និងថ្នាក់ធិបឌិន្ទចំនួន ០១គ្រឿង) មេដាយសេនាជ័យសិទ្ធចំនួន ១៧គ្រឿង មេដាយស្ថាបនាជាតិចំនួន ៤៩គ្រឿង (មេដាយមាសចំនួន ២៦គ្រឿង មេដាយប្រាក់ចំនួន ១៥គ្រឿង និង មេដាយសំរិទ្ធិចំនួន ០៨គ្រឿង) មេដាយមាសការងារចំនួន ៦៨គ្រឿង ដើម្បីផ្ដល់ជូនសប្បុរសជនដែលបានជួយកសាងសមិទ្ធផលជាច្រើន នៅខេត្តស្វាយរៀង ខេត្តកណ្ដាល ខេត្តបាត់ដំបង និងខេត្តព្រៃវែង ដោយចំណាយអស់ថវិកាសរុបចំនួន ៤.៦៧៧.០០២ ដុល្លារ (បួនលានប្រាំមួយរយចិតសិបប្រាំពីរពាន់ពីរដុល្លារសហរដ្ឋអាមេរិក)(ដូចក្នុងឧបសម្ព័ន្ធ ៤)។

**៧.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

**៧.៤.១-កម្មវិធីគាំទ្រដោយអង្គការសហប្រជាជាតិសម្រាប់កុមារ UNICEF**

-រៀបចំកិច្ចប្រជុំពិភាក្សាអន្តរក្រសួងលើសេចក្តីព្រាងកែសម្រួលសេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប

-ចុះសិក្សាពិគ្រោះយោបល់ក្នុងការរៀបចំសេចក្តីណែនាំបំពេញបន្ថែមលើសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ឃុំ សង្កាត់ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនៅខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប និងខេត្តកំពង់ធំ

-សហការរៀបចំសិក្ខាសាលាស្តីពីការដាក់បញ្ចូលគម្រោងសេវាសង្គមទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត នៅខេត្តកំពង់ចាម។

-បានផ្ញើលិខិតជម្រាបជូនទៅរដ្ឋបាលរាជធានី ខេត្តផ្តល់កិច្ចសហការគាំទ្រដល់កិច្ចដំណើរការចុះសិក្សាស្រាវជ្រាវស្តីពីផលប៉ះពាល់នៃជំងឺកូវីដ-១៩លើស្ថានភាពសេដ្ឋកិច្ចសង្គមនៅរាជធានី ខេត្តរបស់អង្គការយូនីសេហ្វ និងមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ដើម្បីធ្វើការសម្ភាសន៍ដោយផ្ទាល់មាត់ និងតាមរយៈលេខទូរស័ព្ទជាមួយប្រជាពលរដ្ឋចំនួន ២.០៨០គ្រួសារ (២៤០ភូមិ) នៅតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តរហូតដល់ការសិក្សាស្រាវជ្រាវត្រូវបានបញ្ចប់។

**៧.៤.២-គម្រោងសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP**

គិតត្រឹមខែកក្កដា ឆ្នាំ២០២០នេះ ការវិវឌ្ឍ នៃដំណើរការការដ្ឋានសាងសង់អគាររដ្ឋបាលអគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ គិតជារួមបានប្រមាណ៧៧ភាគរយ ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានចាត់មន្ត្រីៈ

-ចុះពិនិត្យតាមដានដំណើរការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ ដំណាក់កាលទី១ ទី២ និងទី៣។

-ចុះពិនិត្យការដ្ឋានសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ ដែលបានបញ្ចប់ការសាងសង់ដើម្បីត្រៀមរៀបចំពិធីប្រគល់-ទទួល។

-បានរៀបចំចុះកិច្ចសន្យាបន្តរយៈពេល ០៦ខែ សម្រាប់ទីប្រឹក្សាបច្ចេកទេសគម្រោងចំនួន ០៦រូប និងអ្នកបើកបររថយន្តគម្រោងចំនួន០៤រូប។

**៧.៥-ការងារគម្រោងមូលនិធិ និងការគាំទ្រក្រុង ស្រុក ឃុំ សង្កាត់**

**៧.៥.១-គម្រោងក្រុង ស្រុក**

ការរៀបចំគម្រោងក្រុង ស្រុក ឆ្នាំ២០២០ មានចំនួន ៤៣៨គម្រោង ដែលក្នុងនោះៈ គម្រោងមិនទាន់សិក្សាចំនួន **៥០គម្រោង** (ស្មើនឹង១១.៤២%) គម្រោងកំពុងដំណើរការសិក្សាចំនួន **១៧២គម្រោង** (ស្មើនឹង ៣៩.២៧%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **២១៦គម្រោង**(ស្មើនឹង៤៩.៣២%)ហើយក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សាមានគម្រោងចំនួន **៨៣គម្រោង**(ស្មើនឹង៣៨.៨៣%)បានដេញថ្លៃរួចរាល់។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០២០ មានចំនួន ៣៨កិច្ចសន្យា ក្នុងនោះរួមមានៈ បញ្ចប់ការសាងសង់១០០% ចំនួន ០៧កិច្ចសន្យា(ស្មើនឹង ១៨.៤២%) អនុវត្តបានលើសពី៥០% ចំនួន ១២កិច្ចសន្យា(ស្មើនឹង៣១.៥៨%)អនុវត្តបានតិចជាង៥០% ចំនួន ០៦កិច្ចសន្យា(ស្មើនឹង ១៥.៧៩%) និងមិនទាន់បានអនុវត្តចំនួន ១៣កិច្ចសន្យា(ស្មើនឹង៣៤.៨១%)។ ជាមួយគ្នានេះដែរ សំណើគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ ២០១៩មានចំនួន ៥៣៥គម្រោង ដែលក្នុងនោះៈគម្រោងមិនទាន់សិក្សាចំនួន២៩គម្រោង(ស្មើនឹង៥,៤២%) គម្រោងកំពុងដំណើរការសិក្សាចំនួន ០៥គម្រោង(ស្មើនឹង០.៩៣%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **៥០១គម្រោង**(ស្មើនឹង៩៣.៦៤%) ហើយបានដេញថ្លៃរួចចំនួន **៥០០គម្រោង**(ស្មើនឹង៩៩.៨០%) នៃគម្រោងដែលបានបញ្ចប់ការសិក្សា។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងក្រុង ស្រុកឆ្នាំ២០១៩មានចំនួន ៤៩៩កិច្ចសន្យា ក្នុងនោះរួមមានៈ បញ្ចប់ការសាងសង់១០០% ចំនួន ៤៨៣កិច្ចសន្យា(ស្មើនឹង៩៦.៨០%) អនុវត្តបានលើស៥០% ចំនួន ០៨កិច្ចសន្យា (ស្មើនឹង១.៦០%)អនុវត្តបានតិចជាង៥០%ចំនួន០២កិច្ចសន្យា(ស្មើនឹង ០.៤០%) និងមិនទាន់បានអនុវត្តចំនួន ០៦កិច្ចសន្យា(ស្មើនឹង១.២០%)។

**៧.៥.២-គម្រោងមូលនិធិឃុំ សង្កាត់**

ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២០ មានចំនួន ២.០១៩គម្រោង(ក្នុងនោះកំពុងដំណើរការសិក្សាចំនួន **៧៥៦គម្រោង** (ស្មើនឹង៣៧,៤៤%) មិនទាន់ចាប់ផ្តើមសិក្សាចំនួន **១៤០គម្រោង** (ស្មើនឹង៦,៩៣%) និងបានបញ្ចប់ការសិក្សាចំនួន ១.១២៣គម្រោង(ស្មើនឹង៥៥.៦២%) ហើយបានដេញថ្លៃរួចរាល់ចំនួន ៥១២គម្រោង (ស្មើនឹង៤៥.៥៩%) នៃគម្រោងដែលបានបញ្ចប់ការសិក្សា ។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០២០សរុបចំនួន ៣០៧កិច្ចសន្យា ក្នុងនោះរួមមានៈ បានបញ្ចប់ការសាងសង់ ១០០%ចំនួន ៣៣កិច្ចសន្យា(ស្មើនឹង ១០.៧៥%) ការអនុវត្តបានលើសពី៥០% ចំនួន៦១កិច្ចសន្យា(ស្មើនឹង១៩.៨៧%) អនុវត្តបានតិចជាង៥០%ចំនួន ៤៩កិច្ចសន្យា (ស្មើនឹង១៥.៩៦%) និងមិនទាន់បានអនុវត្តចំនួន ១៦៤កិច្ចសន្យា (ស្មើនឹង៥២.៤២%) ។ ដោយឡែកការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៩មានចំនួន ១.៨០៧គម្រោង (ក្នុងនោះបញ្ចប់ការសិក្សាចំនួន១.៨០៧គម្រោង(ស្មើនឹង១០០%) និងបានដេញថ្លៃរួចរាល់ចំនួន ១.៧៩៤គម្រោង (ស្មើនឹង៩៩.២៨%) ។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៩ មានចំនួន១.៧៩១កិច្ចសន្យាក្នុងនោះរួមមានៈ បានបញ្ចប់ការសាងសង់១០០%ចំនួន១.៦៦៣កិច្ចសន្យា (ស្មើនឹង ៩២,៨៥%) ការអនុវត្តបានលើសពី៥០%ចំនួន ៩៣កិច្ចសន្យា (ស្មើនឹង៥,១៩%) ការអនុវត្តបានតិចជាង៥០%ចំនួន ២៦ កិច្ចសន្យា(ស្មើនឹង១,៤៥%)មិនទាន់បានអនុវត្តចំនួន០៩កិច្ចសន្យា(ស្មើនឹង០,៥០%)។

### ៧.៦-ការផ្តល់សេវា និងការដោះស្រាយវិវាទនៅមូលដ្ឋាន

#### ៧.៦.១-ការផ្ទេរមុខងារ និងធនធាន

-កំពុងសិក្សា និងរៀបចំសេចក្តីព្រាងសេចក្តីណែនាំ ដើម្បីអនុវត្តមុខងារក្នុងវិស័យដែនដី នគរូបនីយកម្ម និងសំណង់នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-បានបន្តសហការជាមួយទីប្រឹក្សារបស់ធនាគារពិភពលោក ពិភាក្សាលើការរៀបចំគម្រោងគ្រប់គ្រងសំរាមសំណល់រឹង និងសំណល់ផ្លាស្ទិក។

#### ៧.៦.២-ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយ

##### ក.ការផ្តល់សេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយ

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ អង្គភាពច្រកចេញចូលតែមួយទាំង២៥រាជធានី ខេត្តបានផ្តល់សេវារដ្ឋបាលសរុបចំនួន ៤៦.៨៣២សេវា ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា **វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**ផ្តល់សេវាបានច្រើនជាងគេគឺចំនួន ២៣.៨៦៩សេវា(ស្មើនឹង ៥០,៩៧%) បន្ទាប់មកវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ៩.៣០៨សេវា (ស្មើនឹង១៩,៨៨%) ចំពោះវិស័យវប្បធម៌ផ្តល់សេវាបានតិចជាងគេគឺចំនួន ០៣សេវា (ស្មើនឹង០,០១%)(ដូចក្នុងឧបសម្ព័ន្ធ៥)។ ជាមួយគ្នានេះដែរ អង្គភាពច្រកចេញចូលតែមួយទាំង ២៥រាជធានី ខេត្តទទួលបានចំណូលសរុបចំនួន៦.០១៩. ៥៦៨.០៦៥រៀល (ស្មើនឹង១.៥០៤.៨៩២,០២ដុល្លារអាមេរិក) ក្នុងនោះបើប្រៀបធៀបចំណូលដែលទទួលបាននៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា **វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**ទទួលបានចំណូលខ្ពស់ជាងគេគឺចំនួន ៤.៦៤៦.៧៣៨.៤៦៥រៀល(ស្មើនឹង៧៧,១៩%) បន្ទាប់មក**វិស័យសាធារណការនិងដឹកជញ្ជូន**ទទួលបានចំណូលចំនួន ៥១២.៣៨៣.០០០រៀល (ស្មើនឹង ៨,៥១%) ។ ចំពោះវិស័យវប្បធម៌ និងវិចិត្រសិល្បៈទទួលបានចំណូលតិចជាងគេគឺចំនួន ៦០០.០០០រៀល(ស្មើនឹង០,០១%)(ដូចក្នុងឧបសម្ព័ន្ធ ៦)។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តសកម្មភាពមួយចំនួន ដើម្បីគាំទ្រដល់អង្គភាពច្រកចេញចូលតែមួយដូចខាងក្រោម៖

-បានប្រជុំពិភាក្សាជាមួយតំណាងក្រុមហ៊ុន KESS Innovation PLC ស្តីពីសំណើសុំភ្ជាប់ប្រព័ន្ធសេវាទូទាត់វិក្កយប័ត្រសម្រាប់ការផ្តល់សេវាតាមអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-បានបញ្ចប់ការធ្វើបច្ចុប្បន្នភាពសេវារដ្ឋបាលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អង្គភាពច្រកចេញចូល-តែមួយរាជធានី ខេត្ត

-បានចុះពិនិត្យមើលការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយ និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋនៅខេត្តកំពង់ធំ ។

##### ខ.ការផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយ

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ ក្នុងចំណោមការិយាល័យច្រកចេញចូលតែមួយចំនួន ១១៥គោលដៅ មានការិយាល័យច្រកចេញចូលតែមួយចំនួន៩៧គោលដៅ បានផ្តល់សេវារដ្ឋបាលសរុបចំនួន ១៤៩.៣៤០សេវា បើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា **វិស័យនីត្យានុកូលកម្ម**បានផ្តល់សេវាបានច្រើនជាងគេគឺចំនួន ១០១.២៩១សេវា (ស្មើនឹង ៦៧,៨៣%) បន្ទាប់មកវិស័យអគ្រានុកូលដ្ឋានចំនួន ៣៧.៩៥៧ សេវា (ស្មើនឹង២៥,៤២%) ចំពោះវិស័យអប់រំបានផ្តល់សេវាតិចជាងគេចំនួន ០៩សេវា(ស្មើនឹង០,០១%)(ដូចក្នុងឧបសម្ព័ន្ធ ៧)។ រយៈពេលដូចគ្នានេះដែរ ក្នុងចំណោមការិយាល័យច្រកចេញចូលតែមួយទាំង១១៥គោលដៅ មានការិយាល័យច្រកចេញចូលតែមួយចំនួន ៩៧គោលដៅទទួលបានប្រាក់ចំណូលសរុបចំនួន ១.១៩៥.៦៩៥ .៦៤០រៀល (ស្មើនឹង២៩៨.៩២៣,៩១ដុល្លារអាមេរិក) បើប្រៀបធៀបចំណូលដែលទទួលបានពីវិស័យទាំង១៤ ឃើញថា វិស័យសុរិយោដីមានចំណូលខ្ពស់ជាងគេគឺចំនួន ៥៧៧.៧២០.០០០រៀល (ស្មើនឹង៤៨,៣២%) បន្ទាប់មក **វិស័យសំណង់**ទទួលបានចំណូលចំនួន ២៨៧.៧០៦.០០០រៀល(ស្មើនឹង ២៤,០៦%) ចំពោះវិស័យអប់រំទទួលបានចំណូលតិចជាងគេចំនួន ១.៤០០.០០០រៀល(ស្មើនឹង០,១១៧%)(ដូចក្នុងឧបសម្ព័ន្ធ៨)។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តសកម្មភាពមួយចំនួន ដើម្បីគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយដូចខាងក្រោម៖

-បានរៀបចំលិខិតទៅរដ្ឋបាលខេត្តព្រៃវែង ឱ្យធ្វើសេចក្តីរាយការណ៍អំពីចំណាត់ការរបស់រដ្ឋបាលខេត្តពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៃការផ្តល់សេវារដ្ឋបាលលើវិស័យសំណង់ និងវិស័យសុរិយោដីនៅការិយាល័យច្រកចេញចូលតែមួយស្រុកពាមរក៏នៃខេត្តព្រៃវែង

-បានគាំទ្រដល់រដ្ឋបាលខណ្ឌមានជ័យ ក្នុងការធ្វើបច្ចុប្បន្នភាពសេវា ក្នុងវិស័យពាណិជ្ជកម្ម

-បានចូលរួមសហការជាមួយក្រសួងរ៉ែ និងថាមពលរៀបចំសេចក្តីព្រាង សេចក្តីណែនាំ ទម្រង់បែបបទ និងនីតិវិធីសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងវិស័យរ៉ែ និងថាមពល

-បានគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយខណ្ឌកំបូល ខណ្ឌឫស្សីកែវ ស្រុកមោងឫស្សី ស្រុកកោះធំ ស្រុកកំរៀង ដើម្បីដោះស្រាយបញ្ហាប្រព័ន្ធ MIS

-បានចុះពិនិត្យមើលការផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយ និងការរៀបចំការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋក្រុងកោះរ៉ុង និងស្រុកកំពង់សិលានៃខេត្តព្រះសីហនុ ។

**៧.៦.៣-ការដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

**ក).ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តទាំង២៥គោលដៅបានទទួលបណ្តឹង សំណូមពរ ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធសរុបចំនួន **៩៨ករណី** ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន ៣៩ករណី(បញ្ចប់ការដោះស្រាយ ៣៣ករណី កំពុងដោះស្រាយ ០៦ករណី) បណ្តឹងក្រៅសមត្ថកិច្ចចំនួន ២៧ករណី ព័ត៌មានផ្សេងៗចំនួន ៣២ករណី(ការសរសើរចំនួន 0ករណី សំណូមពរចំនួន ១៣ករណី និងការសាកសួរព័ត៌មានចំនួន ១៩ករណី) ចំពោះបណ្តឹងក្នុងសមត្ថកិច្ចដែលនៅសល់ខែកន្លងមកបានបញ្ចប់ការដោះស្រាយក្នុងខែកក្កដានេះមានចំនួន ០២ករណី(សរុបរួមបណ្តឹងកំពុងបន្តដោះស្រាយចំនួន ២២ករណីទៀត)(ដូចក្នុងឧបសម្ព័ន្ធ ៩)។ ទន្ទឹមនេះ **អគ្គនាយកដ្ឋានរដ្ឋបាល** ក៏បានអនុវត្តកិច្ចការចាំបាច់មួយចំនួនដើម្បីគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដូចខាងក្រោម៖

-បានគាំទ្រដំណើរការបោះឆ្នោតជ្រើសរើសអនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត ចំនួន០៣ គឺខេត្តកំពត ខេត្តកោះកុង និងខេត្តកណ្តាល។

-បានរៀបចំលិខិតទៅរដ្ឋបាលខេត្តត្បូងឃ្មុំ ដើម្បីចាត់ក្រុមការងារធ្វើការសិក្សាស្រាវជ្រាវលើករណីបណ្តឹងពាក់ព័ន្ធសំណង់ផ្ទះល្វែងគ្មានច្បាប់អនុញ្ញាតមួយកន្លែង ស្ថិតនៅភូមិទន្លេបិទក្រោម ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

-បានចុះសិក្សាវាយតម្លៃលើសមត្ថភាព និងលទ្ធភាពរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងការប្រើប្រាស់ និងគ្រប់គ្រងយន្តការផ្តល់មតិយោបល់ត្រឡប់របស់ប្រជាពលរដ្ឋ លើការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ(ដោយប្រើកម្មវិធីទូរស័ព្ទ) នៅខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តព្រៃវែង ខេត្តកំពត និងរាជធានីភ្នំពេញ។

**ខ).ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ**

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌទាំង៩៧គោលដៅក្នុងចំណោម១១៥គោលដៅបានទទួលបណ្តឹង សំណូមពរ ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធសរុបចំនួន៨៥៦ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន ០៨ករណី (បញ្ចប់ការដោះស្រាយ ០៨ករណី) និងបណ្តឹងក្រៅសមត្ថកិច្ចចំនួន ០៨ករណី ការសាកសួរព័តមានផ្សេងៗចំនួន ៨៤០ករណី (ការសរសើរចំនួន ២៥ករណី សំណូមពរចំនួន ៧៥ករណី ការសាកសួរព័ត៌មានផ្សេងៗចំនួន ៧៤០ករណី)។ ជាមួយគ្នានេះ អគ្គនាយក-ដ្ឋានរដ្ឋបាល ក៏បានអនុវត្តកិច្ចការចាំបាច់មួយចំនួន ដើម្បីគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌដូចខាងក្រោម៖

-បានរៀបចំសំណើសុំប្រកាសទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋក្រុងពោធិ៍សាត់

-បានគាំទ្រដំណើរការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋខណ្ឌ ចំនួន០៤ នៃរដ្ឋបាលរាជធានីភ្នំពេញដែលផុតអាណត្តិការងារ

-បានរៀបចំវគ្គតម្រង់ទិសស្តីពីបែបបទ និងនីតិវិធីនៃការសម្រុះសម្រួលដោះស្រាយបណ្តឹង និងការកត់ត្រាបណ្តឹងនៅគុពិសេសរបស់ការិយាល័យប្រជាពលរដ្ឋ ដល់ប្រធានការិយាល័យ ប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ គោលដៅចាស់ចំនួន ៨៣គោលដៅ។

**៨-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានធ្វើលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ន អង្គភាពនានាដូចខាងក្រោម៖

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ករណី៖

- វិវាទដីធ្លីស្ថិតក្នុងភូមិសាស្ត្រស្រុកបុទុមសាគរ ស្រុកគិរីសាគរ ស្រុកស្រែអំបិល និងស្រុកថ្មបាំង ខេត្តកោះកុង។
- របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណកម្មប្រជាពលរដ្ឋរងគ្រោះចំនួន ៨២គ្រួសារ ដែលបានបាត់បង់លំនៅឋានដោយសារបាក់ច្រាំងទន្លេ ស្ថិតនៅភូមិអន្លង់សំឡី ឃុំខ្ពបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ករណីសំណើសុំចាត់ឯកឧត្តម **លេង វី** ចូលរួមជាសមាជិកគណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម។

-រដ្ឋបាលខេត្តកែប កំពត និងខេត្តព្រះសីហនុ ករណីអគ្គលេខាធិការដ្ឋានរដ្ឋសភា ស្នើសុំសម្របសម្រួលការចុះបំពេញបេសកកម្មរបស់គណៈកម្មការទី១ នៃរដ្ឋសភា។

**៩.ការងារតាមវិស័យផ្សេងៗ**

**៩.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងប័ណ្ណព្រំដែន**

**ក.ការងារច្រកទ្វារព្រំដែន**

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារព្រំដែនសរុបចំនួន ៨២ច្រក រួមមានច្រកទ្វារកំពង់ផែអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារព្រំដែនអន្តរជាតិចំនួន ២៦ច្រក ច្រកទ្វារព្រំដែនទ្វេភាគីចំនួន ១៤ច្រក ច្រកទ្វារតំបន់ព្រំដែនចំនួន ២៦ច្រក និងច្រកទ្វារកំពង់ផែសមុទ្រចំនួន ១០ច្រក។ ដើម្បីគាំទ្រដល់ការងារគ្រប់គ្រងច្រកទ្វារព្រំដែន អគ្គនាយកដ្ឋានរដ្ឋបាល បានអនុវត្តការងារមួយចំនួនដូចខាងក្រោម៖

-បានស្នើឱ្យ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចាត់តំណាងចូលរួមពិនិត្យ និងវាយតម្លៃ ដើម្បីទទួលយកអគារទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ ស្ថិតនៅក្នុងភូមិអូរ ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

-បានជូនដំណឹងដល់គណៈកម្មាធិការចំរុះកិច្ចការព្រំដែន ករណីព័ត៌មាន និងទិន្នន័យបច្ចុប្បន្នភាព នៃការបោះតង់ឬប៉ុស្តិ៍យាមរបស់ភាគីវៀតណាម នៅតាមតំបន់ព្រំដែនកម្ពុជា-វៀតណាម។

-បានជូនដំណឹងទៅរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ចំពោះករណីរាជរដ្ឋាភិបាលកម្ពុជាអនុញ្ញាតឱ្យពលរដ្ឋវៀតណាមចូលមកកម្ពុជា។

**ខ.ការងារប័ណ្ណព្រំដែន**

គិតចាប់ពីថ្ងៃទី១៩ ខែមិថុនា ដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃបានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋប្រើប្រាស់ជាផ្លូវការសរុបចំនួន ៥៧២ប័ណ្ណ (ក្នុងនោះខេត្តបាត់ដំបង២៧៣ប័ណ្ណ ខេត្តបន្ទាយមានជ័យ១៤៦ប័ណ្ណ ខេត្តឧត្តរមានជ័យ៨៦ប័ណ្ណ ខេត្តប៉ៃលិន៤៤ប័ណ្ណ និងខេត្តកោះកុងចំនួន ២៣ប័ណ្ណ)។ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានធ្វើការបន្តសុពលភាពប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋ ដើម្បីចេញចូលឆ្លងកាត់ព្រំដែនកម្ពុជា-ថៃបានចំនួន១៣ប័ណ្ណ។

### ៩.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីបង្កើនទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាពជាមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសនានាជាមិត្ត ក្រសួងមហាផ្ទៃបានធ្វើលិខិតជម្រាបជូនក្រសួងស្ថាប័ន និងរដ្ឋបាលខេត្ត ដូចខាងក្រោម៖

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ករណីស្ដីពីការពន្យាពេលរៀបចំកិច្ចប្រជុំលើកទី១១ ស្ដីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម។

-រដ្ឋបាលខេត្តមណ្ឌលគិរី ករណីស្ថានទូតឡាវនៅកម្ពុជាស្នើសុំជួបសម្ដែងការគួរសមជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណីដំណើរបំពេញទស្សនកិច្ចរបស់ប្រតិភូស្ថានទូតថៃ នៅខេត្តបន្ទាយមានជ័យ

-រដ្ឋបាលខេត្តសៀមរាប ករណីស្នើសុំគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលក្រុងសៀមរាប ខេត្តសៀមរាប ចុះហត្ថលេខាលើកិច្ចព្រមព្រៀងចងសម្ព័ន្ធមេត្រីភាពជាមួយក្រុងតាថុង ខេត្តសានស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។

-រដ្ឋបាលខេត្តឧត្តរមានជ័យ ករណីសំណើសុំគោលការណ៍អនុញ្ញាតឱ្យប្រតិភូខេត្តឧត្តរមានជ័យ ទៅចូលរួមកិច្ចប្រជុំពិភាក្សាការងារ គ្រប់គ្រងប្រព័ន្ធបញ្ជូនអ្នកជំងឺ និងការឆ្លើយតបសង្គ្រោះបន្ទាន់ផ្នែកសុខាភិបាល ខេត្តជាប់ព្រំដែន( Provincial Border Health Committee,Surin-Oddar Meanchey ) នៅខេត្តសុរិន្ទ នៃព្រះរាជាណាចក្រថៃ។

### ៩.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ

ក្នុងខែកក្កដា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានពិនិត្យ សម្រេចផ្ដល់អនុលោមភាពលើគម្រោងអភិវឌ្ឍឆ្នាំ២០២០របស់ខេត្តបាត់ដំបងចំនួន ១៤គម្រោង ដែលមានទឹកប្រាក់សរុបចំនួន ១០.០៤៧.៣០០.០០០រៀល (ដប់ប៊ីលានសែសិបប្រាំពីរលានបីរយពាន់រៀលគត់)(ដូចក្នុងឧបសម្ព័ន្ធ១០)។ ជាមួយគ្នានេះដែរ ក្រសួងក៏បានពិនិត្យសម្រេចផ្ដល់អនុលោមភាពផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) អាណត្តិទី៣របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ខេត្តព្រៃវែង តាកែវ ក្រចេះ ត្បូងឃ្មុំ កំពត និងខេត្តស្ទឹងត្រែង ។ ទន្ទឹមនឹងនោះ អគ្គនាយកដ្ឋានរដ្ឋបាលបានធ្វើលិខិតស្នើសុំគោលការណ៍ដឹកនាំដ៏ខ្ពង់ខ្ពស់ស្ដីពីការអនុវត្តសកម្មភាពមួយចំនួន ដើម្បីគាំទ្រដល់ការងារវិនិយោគ និងអន្តរវិស័យដូចខាងក្រោម៖

-សម្ដេចតេជោនាយករដ្ឋមន្ត្រី៖ ករណីរដ្ឋបាលខេត្តកំពង់ឆ្នាំង ស្នើសុំកាត់ដីទំហំ ១៥ហិកតា ចេញពីដីជាប់តំបន់វាលទំនាបដែលលិចទឹកក្នុងរដូវទឹកជំនន់ឡើងនៃដី ដែលទទួលរបបទឹកទន្លេមេគង្គ ដើម្បីរៀបចំវិនិយោគសាងសង់ផ្សារផែដឹកជញ្ជូន ផែត្រី/កសិផល និងផែទេសចរណ៍សម្រាប់ប្រជាពលរដ្ឋប្រកបអាជីវកម្ម ស្ថិតនៅឃុំឆ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។

-រដ្ឋបាលខេត្តស្ទឹងត្រែង ស្នើសុំគោលការណ៍ដោះដូរដីរបស់រដ្ឋបាលខេត្តស្ទឹងត្រែងទំហំ ៥៩,៤៤ហិកតា ស្ថិតនៅភូមិគីឡូ៨ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ជាមួយដីកាគីឯកជនចំនួន ២០០ឡូតិ៍ ដែលក្នុងមួយឡូតិ៍ទំហំ ៥ម៉ែត្រ x ២០ម៉ែត្រ ស្ថិតនៅភូមិរាជានុកុល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

-រដ្ឋបាលខេត្តបាត់ដំបង ករណីសំណើសុំ៖

• ស្ថាបនាសំណង់ទំនប់បង្ហៀរស្ទឹងមង្គលបុរី (ស្ទឹងម្ចាស់កាល) ប្រសព្វនឹងស្ទឹងកំរៀងចំនួន ០១កន្លែង មានមុខកាត់ទទឹងស្ទឹងប្រវែង២៤ម៉ែត្រ និងកម្ពស់១០ម៉ែត្រ ស្ថិតនៅក្នុងឃុំអូរដា និងឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង។

• កាត់ដីចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តបាត់ដំបង នូវផ្ទៃដីទំហំ៥៣.៦០០ម៉ែត្រការ៉េ ស្ថិតនៅភូមិកគោ ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ដើម្បីផ្ដល់ជូនលោក ហុង ឡុង ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ហុង ឡុង។

• ខេត្តបន្ទាយមានជ័យ ករណីសាងសង់សំណាកប្រាសាទកំពូលបី (ប្រាសាទហាន់សួគ៌) ស្ថិតនៅរង្វង់មូលប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

-បានធ្វើលិខិតជូនដំណឹងដល់រដ្ឋបាលខេត្តកំពង់ស្ពឺ ករណីសាងសង់អគារសាលាឃុំ សង្កាត់ចំនួន ០៣ គឺ សាលាសង្កាត់ស្វាយក្រវ៉ាន់ សាលាសង្កាត់កណ្ដោលដុំ ក្នុងក្រុងច្បារមន និងសាលាឃុំក្រាំងដីវ៉ាយ ក្នុងស្រុកភ្នំស្រួច ដោយប្រើប្រាស់ថវិការបស់រដ្ឋបាលខេត្តឆ្នាំ២០២០ជំនួសមូលនិធិទ្រទ្រង់ថវិកាឆ្នាំ២០១៦-២០១៩នៃគម្រោងសាងសង់អគាររដ្ឋបាលសាលាស្រុក និងអគាររដ្ឋបាលសាលាឃុំ សង្កាត់(DCFP)របស់អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ។-

-បានផ្ញើលិខិតជូនដំណឹងដល់រដ្ឋបាលខេត្តកំពង់ចាម ករណីសំណើសុំរុះរើ និងជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នូវអគារផ្ទះភ្ញៀវចំនួន១ខ្នង និងអគារការិយាល័យចំនួន៤ របស់រដ្ឋបាលស្រុកជើងព្រៃ ខេត្តកំពង់ចាម

-បានផ្ញើលិខិតជូនដំណឹងដល់រដ្ឋបាលខេត្តកណ្ដាល ករណីសំណើសុំជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋនូវអគារ០១ខ្នងទំហំ ៨,២០ម៉ែត្រ x ២៩,៧០ម៉ែត្រ របស់រដ្ឋបាលស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

**៩.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ**

**៩.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**

គិតមកដល់បច្ចុប្បន្នសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជី នៅក្រសួងមហាផ្ទៃសរុបចំនួន ៥.៦៨៣(ក្នុងនោះសមាគមចំនួន ២.៣៣១ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣.៣៥២) និងសហគមន៍ជនជាតិដើមភាគតិចចំនួន១៥០ (**ដូចក្នុងឧបសម្ព័ន្ធ១១**)។ ក្នុងខែកក្កដា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានសម្រេចចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៣ (ក្នុងនោះសមាគម ១០ អង្គការមិនមែនរដ្ឋាភិបាល ៣) ព្រមទាំងលុបឈ្មោះអង្គការចំនួន ០១ (**ដូចក្នុងឧបសម្ព័ន្ធ១១**)។

ទន្ទឹមនេះ ក៏បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេចពាក់ព័ន្ធនឹងការងារនានា ដូចជាការសុំចុះឈ្មោះក្នុងបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល ការសុំទទួលស្គាល់ប្រធាន ការសុំផ្លាស់ប្តូរសមាសភាពថ្មី នៃរចនាសម្ព័ន្ធ ការសុំធ្វើវិសោធនកម្មលក្ខន្តិកៈ ការសុំបើកទីស្នាក់ការសាខា ការសុំប្តូរឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការលុបឈ្មោះ ការផ្អាកសកម្មភាពបណ្តោះអាសន្នចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។ ព្រមទាំងបានបញ្ចូលទិន្នន័យស្កេនសំណុំឯកសារពាក់ព័ន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន **២១ច្បាប់** ក្នុងនោះសមាគមចំនួន **១១ច្បាប់** និងអង្គការមិនមែនរដ្ឋាភិបាលចំនួន **១០ច្បាប់**។

**៩.៤.២-ការងារគណបក្សនយោបាយ**

គិតមកដល់បច្ចុប្បន្នគណបក្សនយោបាយមានចំនួនសរុប ៤៦គណបក្ស ក្នុងនោះគណបក្សដែលបានចុះបញ្ជីចំនួន៤៥គណបក្ស និងគណបក្សដែលបានបង្កើតចំនួន ០១គណបក្ស (**ដូចក្នុងឧបសម្ព័ន្ធ១១**)។ ក្នុងខែកក្កដា ឆ្នាំ២០២០នេះ បានបញ្ចូលទិន្នន័យស្កេនសំណុំឯកសារពាក់ព័ន្ធរបស់គណបក្សនយោបាយចំនួន០២គឺ**គណបក្សខ្មែរស្រលាញ់ជាតិ និងគណបក្សប្រជាធិបតេយ្យមូលដ្ឋាន**។

## II-<u>បញ្ហាប្រឈម និងសំណូមពរ</u>

ទន្ទឹមនឹងការសម្រេចលទ្ធផលដូចខាងលើ ក្នុងការបំពេញភារកិច្ចកន្លងមក អគ្គនាយកដ្ឋានរដ្ឋបាលបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

-មិនទាន់បានដាក់ចេញគំរូពាក្យស្នើសុំ និងគំរូអាជ្ញាប័ណ្ណស្តង់ដាររួមសម្រាប់ការផ្តល់សេវារដ្ឋបាល នៅអង្គភាពច្រកចេញចូលតែមួយ

-ទិន្នន័យផ្ទុកក្នុងប្រព័ន្ធ MIS កាន់តែច្រើនទៅៗធ្វើឱ្យប្រព័ន្ធ MIS ដំណើរការយឺតពិបាកក្នុងការផលិតរបាយការណ៍ចេញ

-ការផ្គត់ផ្គង់សម្ភារការិយាល័យដូចជាក្រដាស ទឹកថ្នាំ ម៉ាស៊ីនថតចម្លង ដើម្បីឆ្លើយតបសំណូមពរការងារមិនទាន់បានគ្រប់គ្រាន់ហើយការបើកសម្ភារៈពុំសូវមានគុណភាព

-ការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មសម្រាប់មន្ត្រីចុះបំពេញការងារនៅតាមខេត្ត មន្ត្រីពេលការត្រូវចំណាយថវិកាផ្ទាល់ខ្លួនជាមុនហើយបន្ទាប់ពីបញ្ចប់បេសកកម្មការបើកផ្តល់មានភាពយឺតយ៉ាវ

-មន្ត្រីមិនទាន់មានជំនាញគ្រប់គ្រាន់ ក្នុងការសរសេរព័ត៌មាន និងគ្រប់គ្រងព័ត៌មានវិទ្យា ទាមទារត្រូវការបណ្តុះបណ្តាល

ដើម្បីជំរុញការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកទឹកចិត្តមន្ត្រី ក្នុងការបំពេញការងារ អគ្គនាយកដ្ឋានរដ្ឋបាល សំណូមពរដូចខាងក្រោម៖

-ផ្គត់ផ្គង់សម្ភារការិយាល័យឱ្យបានសមស្រប និងទាន់ពេលវេលាដើម្បីជានាឆ្លើយតបសំណូមពរការងារ

-ផ្តល់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មឱ្យបានលឿនជាងមុនបន្តិចបន្ទាប់ពីចុះបំពេញបេសកកម្ម។

### III-ទិសដៅការងារបន្ត

ដើម្បីជំរុញការអនុវត្តការងារឱ្យបានល្អប្រសើរ និងតាមផែនការដែលបានគ្រោងទុក អគ្គនាយកដ្ឋានរដ្ឋបាល បានដាក់ចេញនូវទិសដៅការងារបន្តសម្រាប់ខែសីហា ឆ្នាំ២០២០ដូចខាងក្រោម៖

**១-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

**១.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុងដែលកំពុងរៀបចំ**

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ និងការកែសម្រួលព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការវាយតម្លៃជ្រើសរើសរដ្ឋបាលក្រុង ស្រុក ខណ្ឌឆ្នើមក្នុងការផ្តល់សេវារដ្ឋបាល

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់

-សេចក្តីព្រាងក្របខ័ណ្ឌស្តីពីការតាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់ទម្រង់ដីកានានាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីជូនដំណឹង ស្តីពីការគ្រប់គ្រងមន្ត្រីរាជការនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌបន្ទាប់ពីការធ្វើសមាហរណកម្មទៅក្នុងចនាសម្ព័ន្ធថ្មី

-សេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក

-សេចក្តីព្រាងសៀវភៅណែនាំស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសៀវភៅណែនាំ ស្តីពី"កិច្ចការរដ្ឋបាល"សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

**១.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងកែសម្រួលប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិកាវង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០២០-២០៣០។

**២-ការងារបុគ្គលិក**

**២.១-ការងារក្របខ័ណ្ឌ**

-បន្តរៀបចំបែបបទសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ និងតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០២០

-បន្តរៀបចំបែបបទសុំដំឡើងឋានន្តរស័ក្តិ ជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទស្នើសុំផ្ទេរក្របខ័ណ្ឌពីមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ទៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗ និងពីក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ដើម្បីទៅបំពេញការងារក្នុងមុខតំណែងថ្មីនិងអនុញ្ញាតឲ្យមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌដើមវិញ

-បន្តរៀបចំបែបបទដើម្បីតាំងស៊ប់ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីសុំពិនិត្យនីត្យានុកូលភាពលើប្រកាសតែងតាំង និងប្រគល់ភារកិច្ច ដើម្បីស្នើសុំផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទផ្តល់ទិដ្ឋាការលើសលាកបត្រជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ។

**២.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល**

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីរាជការដែលទទួលមរណភាពនិងមន្ត្រីរាជការដែលសុំលាឈប់ពីការងារ

-បន្តរៀបចំផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតអនុញ្ញាត ឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញ បន្ទាប់ពីសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីដែលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយហួសកាលកំណត់

-បន្តរៀបចំសំណុំលិខិតអនុញ្ញាតឈប់សម្រាកលំហែមាតុភាព

-បន្តរៀបចំសំណុំបែបបទផ្ទេរកូនកំព្រា និងសុំប្រាក់ជានារ៉ាប់រងសង្គម

-បន្តពិនិត្យផ្ទៀងផ្ទាត់សលាកបត្រមន្ត្រីរាជការស៊ីវិលនិងមន្ត្រីពន្ធនាគារដែលដល់អាយុត្រូវចូលនិវត្តន៍ឆ្នាំ២០២០

-បន្តពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រឿងឥស្សរិយយសមេដាយការងារ និងប័ណ្ណសរសើ ជូនមន្ត្រីរាជការស៊ីវិល។

**២.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាពសម្រាប់ខែបន្ទាប់របស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួង

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាពទីប្រឹក្សា ជំនួយការក្រសួងមហាផ្ទៃ

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាពទីប្រឹក្សា ជំនួយការ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បន្តធ្វើការតែងតាំងទីប្រឹក្សា ជំនួយការ

-បន្តរៀបចំស្នើសុំប្រាក់បៀវត្សទីប្រឹក្សា ជំនួយការ

-បន្តរៀបចំការងារពិពណ៌នាមុខតំណែងមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-បន្តរៀបចំសំណើសុំគោលការណ៍ពិនិត្យសម្រេច លើការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ

-បន្តរៀបចំសំណើសុំគោលការណ៍ពិនិត្យសម្រេចលើការផ្លាស់ប្តូរកន្លែងធ្វើការងាររបស់មន្ត្រីរាជការស៊ីវិល

-រៀបចំដាក់ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិរយៈពេល០៣ខែនិងដាក់ទណ្ឌកម្មខាងវិន័យសម្រាប់មន្ត្រីពន្ធនាគារ

-បន្តរៀបចំសំណើសុំគោលការណ៍ពិនិត្យ សម្រេចលើការផ្អាកការងារដោយផ្អាកបៀវត្ស។

**២.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការចុះពង្រឹងរបៀបរបបការងារ និងការគ្រប់គ្រងមន្ត្រីរាជការ នៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

-ពិនិត្យ និងសិក្សាលើសំណើសុំកែសម្រួលរចនាសម្ព័ន្ធទីចាត់ការ អង្គភាព និងការិយាល័យនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តពិនិត្យ និងលើកយោបល់ ដើម្បីស្នើសុំការសម្រេចលើការតែងតាំងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវដល់អាណត្តិ ០៤ឆ្នាំ(និង០៨ឆ្នាំ)របស់ខ្លួន

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បន្តសហការ និងសម្របសម្រួលជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយលើការងារប្រកាសទ្រព្យសម្បត្តិ និងបំណុលសម្រាប់ឆ្នាំ២០២០។

**២.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តយកចិត្តទុកដាក់ពិនិត្យលើកយោបល់ទាក់ទងការផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានទាន់ពេលវេលា

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

**២.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

-ធ្វើបច្ចុប្បន្នភាពដោយកែតម្រូវព័ត៌មានប្រវត្តិរូបរបស់មន្ត្រីរាជការក្នុងប្រព័ន្ធទិន្នន័យ សម្រាប់រាជធានី ខេត្ត ចំនួន ០៦ រួមមាន៖ ខេត្តសៀមរាប ខេត្តព្រៃវែង ខេត្តកណ្តាល ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ

-បន្តសហការជាមួយក្រុមហ៊ុនក្នុងការរៀបចំប្រព័ន្ធឲ្យមានភាពល្អប្រសើរជាងមុន

-បន្តសហកាជាមួយមន្ត្រីបង្គោល នៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីប្រមូលប្រវត្តិរូបមន្ត្រីកម្មសិក្សាក្របខ័ណ្ឌថ្មី ឆ្នាំ ២០១៩ និងមន្ត្រីដែលទើបផ្ទេរចូលថ្មី រួមទាំងឯកសារមន្ត្រីរាជការដែលមានការប្រែប្រួលស្ថានភាពជាបន្តបន្ទាប់

-បន្តសិក្សា និងរៀបចំភ្ជាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រប់ការិយាល័យដែលពាក់ព័ន្ធ ចំណុះនាយកដ្ឋានបុគ្គលិក

-បន្តសហការជាមួយការិយាល័យជំនាញពាក់ព័ន្ធដើម្បីធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការដូចជា៖ ការផ្លាស់ប្តូរកន្លែងធ្វើការ ការតែងតាំង ការប្រែប្រួលថ្នាក់ ឋានន្តរស័ក្តិ ការលុបឈ្មោះ ការចូលនិវត្តន៍...។ល។

### ៣-ការងារអភិវឌ្ឍន៍សមត្ថភាព

#### ៣.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់រាជធានី ខេត្ត ស្របតាមផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តរៀបចំឯកសារបណ្តុះបណ្តាលកិច្ចការរដ្ឋបាល ការងារបុគ្គលិក និងការងារហិរញ្ញវត្ថុសម្រាប់ក្រុមគោលដៅមន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅអំឡុងត្រីមាសទី៣ ឆ្នាំ២០២០

-បន្តរៀបចំកិច្ចការចាំបាច់នានាសម្រាប់ដាក់ឲ្យដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន(NASLA)

-បន្តសិក្សាស្រាវជ្រាវ និងចងក្រងឯកសារអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា និងបរទេស

-កំពុងរៀបចំប្រមូលទិន្នន័យរបាយការណ៍ស្តីពីការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួង-មហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ត្រីមាសទី១ឆ្នាំ២០២០

-បន្តចងក្រងទិន្នន័យអភិវឌ្ឍសមត្ថភាព

-បន្តរៀបចំវគ្គភាពជាអ្នកដឹកនាំ(វគ្គទី២+វគ្គទី៣) សម្រាប់ក្រុមគោលដៅថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌ។

#### ៣.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន

-បន្តរៀបចំបែបបទដើម្បីបញ្ជូនមន្ត្រីទៅចូលរួមសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅក្រៅប្រទេស

-បន្តសហការជាមួយដៃគូ ដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហការសម្រាប់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការតាមការស្នើសុំពីមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

#### ៣.៣-ការងារផ្សព្វផ្សាយ និងព័ត៌មាន

-បន្តធ្វើបច្ចុប្បន្នភាពនិងបញ្ចូលអត្ថបទក្នុងគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល

-បន្តស្រាវជ្រាវ និងសរសេរអត្ថបទដើម្បីបញ្ចូលទៅក្នុងព្រឹត្តិបត្រ «វិមជ្ឈការ និងវិសហមជ្ឈការ» ក្រសួងមហាផ្ទៃលេខ ០៤។

### ៤-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

#### ៤.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍

ដើម្បីគាំទ្រដល់ការបំពេញតួនាទីភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច និងបន្តអនុវត្តលើកិច្ចការមួយចំនួនដូចខាងក្រោម៖

-រដ្ឋបាលខេត្តព្រះសីហនុ ករណី៖

- រដ្ឋបាលខេត្ត ធ្វើសេចក្តីរាយការណ៍អំពីករណីសំណើសុំចុះពិនិត្យទីតាំង វាស់វែង និងកំណត់ព្រំដីទំហំ ០៥ ហិចតា ៤០អា ដើម្បីចុះបញ្ជី និងចេញប័ណ្ណកម្មសិទ្ធិ ស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
- ឈ្មោះ ស៊ី ផុនគូ និងឈ្មោះ ស៊ី អ៊ីនហួយ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុ និងមន្ទីរពាក់ព័ន្ធ ឱ្យទទួលស្គាល់ឈ្មោះ ស៊ី ផុនគូ និងឈ្មោះ ស៊ី អ៊ីនហួយ ជាអ្នកទទួលសិទ្ធិក្នុងការគ្រប់គ្រងបន្តលើដីចំនួន ២១ប័ណ្ណ ទំហំ ៩៦,៧៣ហិកតា ស្ថិតនៅឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

-បន្តពិនិត្យលើកយោបល់ ករណីស្នើសុំគោលការណ៍អនុញ្ញាតបង្កើតនិមិត្តសញ្ញាខេត្តតាកែវ ពោធិ៍សាត់ ព្រះវិហារ និងការស្នើសុំកែសម្រួលទម្រង់រាង នៃនិមិត្តសញ្ញាខេត្តស្ទឹងត្រែង។

-រដ្ឋបាលខេត្តត្បូងឃ្មុំ ករណីឈ្មោះ មេត អូន និងឈ្មោះ ស្រ៊ុន ហ៊ាង ស្នើសុំជួយរកយុត្តិធម៌ករណីអាជ្ញាធរខេត្តយកដីពួកគាត់ទំហំ ១,២ហិកតា ស្ថិតនៅចំណុចទល់មុខសាកលវិទ្យាល័យ សម្តេច ហេង សំរិន ត្បូងឃ្មុំ ក្នុងភូមិនិគមន៍លើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

-រដ្ឋបាលខេត្តកណ្តាល ករណីឈ្មោះ អៀង ណារិន ស្នើសុំអន្តរាគមន៍ឱ្យរដ្ឋបាលខេត្តកណ្តាល ធ្វើការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដើម្បីបិទបញ្ចប់ការដោះស្រាយវិវាទដីធ្លី ស្ថិតនៅភូមិព្រែកតានប់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

-រដ្ឋបាលខេត្តក្រចេះ ករណីឈ្មោះ មូល កើត, ម៉ី កៅ និងឈ្មោះ ម៉ាត់ លស់ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តក្រចេះ ពាក់ព័ន្ធនឹងការលុបឈ្មោះចេញពីបញ្ជីឈ្មោះប្រជាពលរដ្ឋត្រូវទទួលបានដីសម្បទានសង្គមកិច្ច និងការប្តឹងទៅតុលាការខេត្តកណ្តាល ដោយរដ្ឋបាលខេត្តក្រចេះ។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណីៈ

• មេធាវីឈ្មោះ ម៉ន កែវស៊ីរិន តំណាងឱ្យឈ្មោះ មាស សារឿន ស្នើសុំអន្តរាគមន៍ឱ្យរដ្ឋបាលខេត្តបន្ទាយមានជ័យផ្តល់ប័ណ្ណកម្មសិទ្ធិ និងអនុញ្ញាតឱ្យធ្វើរបង ចាក់ដីបំពេញ និងសង់លំនៅឋានលើទីតាំងដីទំហំ៣៣ហិកតា ស្ថិតនៅភូមិព្រៃព្រិច និងភូមិចាន់គិរី សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

• ធ្វើសេចក្តីរាយការណ៍បំភ្លឺករណីឈ្មោះវិទ្ធ សុគន្ធា ចោទប្រកាន់ឈ្មោះ រ៉េន រើក និងឈ្មោះ អេង សំអឿនអំពីការក្លែងបន្លំឯកសារកំលោកយកដីស្ថិតនៅភូមិខ្លាកូនចាស់ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តស្ទឹងត្រែង ករណីស្នើសុំអន្តរាគមន៍ចាប់ខ្លួនឈ្មោះ សាយ សុគិរី ដែលបានឈូសឆាយដីរដ្ឋទំហំ ១.០០០ហិកតា យកធ្វើជាកម្មសិទ្ធិឯកជន ស្ថិតនៅចំណុចអូរស្ទឹងជ្រៅ ភូមិស្រែស្រណុក ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង

-រដ្ឋបាលខេត្តកំពង់ចាម ករណីធ្វើសេចក្តីរាយការណ៍អំពីការរកឃើញនាវាចំបាំង និងគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះដែលបានលិចក្នុងទន្លេ ស្ថិតនៅភូមិវិាល ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

-រដ្ឋបាលខេត្តកំពង់ឆ្នាំង ករណីៈ

• ការរៀបចំអនុវត្តវិធានការរដ្ឋបាលលើការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុដទៃទៀតតាមច្បាប់អស្សាមិករណ៍ សម្រាប់គម្រោងស្តារឡើងវិញកំណាត់ផ្លូវជាតិលេខ៥

• រដ្ឋបាលខេត្ត ធ្វើសេចក្តីរាយការណ៍អំពីករណីជនល្មើសលួចឈូសឆាយ កាប់ព្រៃ បោះរបង និងសង់ខ្ទមចូលដែនជម្រកសត្វព្រៃឱរ៉ាល់ ស្ថិតក្នុងឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

-រដ្ឋបាលរាជធានីភ្នំពេញ ករណីៈ

• ឈ្មោះ ចេង សុណាត,ឈូក សារ៉ុម,ម៉េង កៅ,លី គីមហួ,លី យ៉ាវ និងឈ្មោះ លី សម្បត្តិ ស្នើសុំអន្តរាគមន៍ដោះស្រាយលើវិវាទដីចិញ្ចឹមត្រី ស្ថិតនៅភូមិដូង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ ជាមួយក្រុមហ៊ុនឡាយឌី

• មេធាវីឈ្មោះ ដារ៉ា សុបញ្ញា ស្នើសុំអន្តរាគមន៍ជួយដោះស្រាយបញ្ហាដីធ្លីទំហំ ១៩២.៥៧៣,៧ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិឌួង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

• ឈ្មោះ ច័ន្ទ រិទ្ធី, ណុប រស្មី, ស្រី សន, យុន ណាន់, សៅ ផល្លា, ណុប កក្រ្កា, សំ ស្រីអូន, ប៉ា ណារ័ត្ន និងឈ្មោះ គង់ ស្រីណា ស្នើសុំអន្តរាគមន៍រុះរើកញ្ចះថ្ម និងតូបទូរស័ព្ទរបស់ឈ្មោះ រិទ្ធ រ៉ាវី ដែលស្ថិតនៅក្នុងចំណតបេនឡានទំហំ៧៦ម៉ែត្រ x ១៩ម៉ែត្រ, ស្នើសុំស្រាវជ្រាវលិខិតផ្ទេរសិទ្ធិចំនួន ១៤គ្រួសារ ដែលទិញពីក្រុមហ៊ុន 7NG និងបញ្ឈប់ការលក់ដូរ និងជួលទីតាំងចំណតឡានក្រុងទាំងមូលនៅមុខផ្ទះ ១៤A1 ដល់២៩A1 ស្ថិតនៅបុរីសន្តិភាព២ ផ្លូវសន្តិភាព ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ។

-រដ្ឋបាលខេត្តពោធិ៍សាត់ ករណីអង្គការ **Wildlife Alliance** ស្នើសុំអន្តរាគមន៍បញ្ឈប់ការលូកដៃក្នុងការងារអនុវត្តច្បាប់របស់មន្ត្រីឧទ្យានុរក្ស និងរបស់ស្ថាប័នតុលាការ។

-បន្តរៀបចំ កែសម្រួលនូវប្រព័ន្ធរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត។

-បន្តរៀបចំបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

-ត្រៀមរៀបចំចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ ក្នុងការិយបរិច្ឆេទ ឆ្នាំ២០២០។

**៤.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

អគ្គនាយកដ្ឋានរដ្ឋបាល បន្តពិនិត្យ និងលើកយោបល់ ជូនថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធនឹងការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការបង្កើតភូមិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោមៈ

-រដ្ឋបាលខេត្តកំពត ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងកំពត និងស្រុកទឹកឈូ។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណីស្នើសុំបង្កើតភូមិថ្មីចំនួន ០២ ស្ថិតក្នុងឃុំណាំតៅ ស្រុកភ្នំស្រុក និងភូមិចំនួន ០៥ ស្ថិតក្នុងឃុំតាគង់ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តតាកែវ ករណីរដ្ឋបាលឃុំកំពង់រាប ស្នើសុំបំបែកភូមិ ចំនួន ០៣ ស្ថិតក្នុងឃុំកំពង់រាប ចំនួន ០២ភូមិ និងឃុំព្រៃល្វា ចំនួន០១ភូមិ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ។

-រដ្ឋបាលខេត្តព្រៃវែង ករណីស្នើសុំបំបែកភូមិចំនួន ០៤ភូមិ ស្ថិតនៅក្នុងឃុំកំពង់ពពិល ចំនួន ០១ភូមិ និងឃុំកញ្ចំ ចំនួន ០៣ភូមិ នៃស្រុកពារាំង ខេត្តព្រៃវែង។

-**រដ្ឋបាលខេត្តសៀមរាប ព្រះវិហារ ឧត្តរមានជ័យ និងខេត្តបាត់ដំបង** ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខេត្តសៀមរាបជាមួយខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង។

-រដ្ឋបាលខេត្តកំពង់ស្ពឺ ករណីស្នើសុំបង្កើតភូមិថ្មីចំនួន ០១ ស្ថិតនៅឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

**៤.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

-បន្តតាមដាន ត្រួតពិនិត្យអំពីការអនុវត្តលិខិតលេខ ១៩៧៣ស.ជ.ណ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការពង្រឹងការគ្រប់គ្រង ការស្នើសុំគ្រឿងឥស្សរិយយសស្ថាបនាជាតិ និងគោរមងារជាឧកញ៉ាជូនសប្បុរសជនដែលមានស្នាដៃ និងគុណបំណាច់ក្នុងការជួយកសាងជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង ករណីសំណើសុំគ្រឿងឥស្សរិយយសរបស់រដ្ឋបាលខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តព្រៃវែង និងខេត្តស្វាយរៀង។

**៤.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

**៤.៤.១-កម្មវិធីគាំទ្រដោយអង្គការ UNICEF**

-រៀបចំសេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

-រៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីកញ្ចប់ថវិកាសេវាសង្គមរបស់រដ្ឋបាលឃុំ សង្កាត់

-រៀបចំឯកសារជំនួយស្មារតីស្តីពីការចុះគាំទ្រ តាមដាន និងវាយតម្លៃការអនុវត្តគម្រោងក្រុង ស្រុក ឃុំ សង្កាត់។

-បន្តរៀបចំប្រព័ន្ធទិន្នន័យគម្រោង របស់រដ្ឋបាលរាជធានី ខេត្ត។

-បន្តធ្វើបច្ចុប្បន្នភាពស្ថានភាពនិងទីតាំងអគាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ប្រចាំត្រីមាសទី១ ឆ្នាំ២០២០។

**៤.៤.២-គម្រោងសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP**

-បន្តតាមដាន និងសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពាក់ព័ន្ធនឹងសំណើសុំថវិកាបន្ថែមដើម្បីរក្សាការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំ និងអគាររដ្ឋបាលឃុំ សង្កាត់តាមចំនួន ដែលបានគ្រោងទុកក្នុងផែនការអនុវត្តរបស់គម្រោង។

-បន្តចុះពិនិត្យតាមដាន និងជំរុញដំណើរការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ សម្រាប់ដំណាក់កាលទី១ ទី២ និងទី៣ឱ្យបានសម្រេច និងទាន់ពេលវេលា តាមផែនការរបស់គម្រោង។

**៤.៥-ការងាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់**

-បន្តផ្ទៀងផ្ទាត់បច្ចុប្បន្នភាពដំណើរការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០២០-២០២២

-បន្តជំរុញការរៀបចំផែនការអភិវឌ្ឍប្រាំឆ្នាំ២០២០-២០២៤របស់រដ្ឋបាលក្រុង ស្រុក

-បន្តគាំទ្រ និងតាមដានដំណើរការសិក្សារៀបចំគម្រោងក្រុង ស្រុក ឃុំ សង្កាត់ និងតាមដានវាយតម្លៃគម្រោង

-បន្តគាំទ្រ និងតាមដានដំណើរការលទ្ធកម្ម និងគ្រប់គ្រងកិច្ចសន្យារបស់រដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់

-បន្តរៀបចំអនុវត្តការតាមដានការអនុវត្តតួនាទីភារកិច្ច និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់

-ពង្រឹង និងពន្លឿនការចាត់ចែង ដោះស្រាយពាក្យបណ្តឹងនានាដែលពាក់ព័ន្ធនឹងក្រុង ស្រុក ឃុំ សង្កាត់។

**៤.៦-ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

-តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-រៀបចំកិច្ចប្រជុំអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន និងលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យ និងផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក

-បន្តសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗ និងលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងដំណើរការរៀបចំផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

-ផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋដល់ក្រុមប្រឹក្សារាជធានី ខេត្ត និងអ្នកពាក់ព័ន្ធ

-រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងការអនុវត្តតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌទាំង ១១៥គោលដៅ។

**៥-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ដើម្បីលើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ននានា អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យ និងលើកយោបល់លើករណីដូចខាងក្រោមៈ

-ត្រៀមសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សា និងរៀបចំទិន្នន័យដើមគ្រានៃការផ្តល់សេវាក្នុងវិស័យសុខាភិបាលនៅមូលដ្ឋាន។

**៦-ការងារតាមវិស័យផ្សេងៗ**

**៦.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងបំណ្តាព្រំដែន**

**ក.ការងារច្រកទ្វារព្រំដែន**

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊ូវ និងព្រែកជ្រៃធំ-ព្រែកប៊ិញយី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។

-បន្តសម្របសម្រួលកិច្ចការនានាចាំបាច់ ដើម្បីត្រៀមរៀបចំពិធីសម្ពោធបើកឱ្យដំណើរការជាផ្លូវការនូវការដំឡើងកម្រិតច្រកទ្វារព្រំដែនម៉ឺនជ័យ(ព្រៃវែង)-តឹនណាម(តៃនីញ)ជាច្រកទ្វារព្រំដែនអន្តរជាតិ។

-សម្របសម្រួលលើការងាររៀបចំកិច្ចប្រជុំក្រុមការងារចម្រុះស្តីពីច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាមលើកទី២។

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេចអំពីលទ្ធផលនៃការចុះសិក្សាពិនិត្យ និងវាយតម្លៃចំពោះករណីរដ្ឋបាលខេត្តកំពត ស្នើសុំបង្កើតច្រកទ្វារព្រំដែនថ្មីចំនួន០២ ស្ថិតក្នុងស្រុកបន្ទាយមាស។

-បន្តសម្របសម្រួលសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តប៉ៃលិន ដើម្បីរៀបចំកិច្ចព្រមព្រៀងនានាសម្រាប់ជម្រុញការសាងសង់ស្ថានថ្មីនៅច្រកទ្វារព្រំដែនអន្តរជាតិព្រំ(ប៉ៃលិន)-បានផាកាដ(ច័ន្ទបុរី)។

ខ.ការងារប័ណ្ណព្រំដែន

-បន្តតាមដាន និងគាំទ្រដល់រដ្ឋបាលខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវអំពីដំណើរការផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ ប្រើប្រាស់ព្រមទាំងបន្តតាមដាននិងសិក្សាលទ្ធភាពក្នុងការផ្តល់សេវាប័ណ្ណព្រំដែននៅរដ្ឋបាលក្រុង ស្រុក និងច្រកទ្វារព្រំដែន នៃបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ។

-បន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យប័ណ្ណព្រំដែនកម្ពុជា/ថៃឱ្យមានភាពប្រសើរឡើង និងប្រសិទ្ធភាពខ្ពស់។

**៦.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-ពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តមណ្ឌលគិរី ស្នើសុំគោលការណ៍ទៅចុះហត្ថលេខាលើកំណត់ហេតុផែនការកិច្ចសហប្រតិបត្តិការដំណាក់កាលឆ្នាំ២០២០-២០២៥ រវាងខេត្តមណ្ឌលគិរី ជាមួយខេត្តដាក់ឡាក់នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

-បន្តតាមដាន ករណីភាគីវៀតណាមបោះតង់ឬប៉ុស្តិ៍យាមតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។

-បន្តសិក្សា និងលើកយោបល់ ករណីទាហានឈុតខ្មៅកងអនុសេនាធំលេខ៥៤១ សាងសង់ប៉ុស្តិ៍សង្កេតការណ៍លើទឹកដីកម្ពុជា ស្ថិតក្នុងភូមិសាស្ត្រ ខេត្តប៉ៃលិន។

- បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៧ ដែលភាគីថៃទទួលធ្វើជាម្ចាស់ផ្ទះក្នុងឆ្នាំ២០២០។

- បន្តសម្របសម្រួលលើការងាររៀបចំកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាមលើកទី១១។

**៦.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ**

ក្នុងខែសីហា ឆ្នាំ២០២០ អគ្គនាយកដ្ឋានរដ្ឋបាល បន្តពិនិត្យ និងលើកយោបល់ចំពោះសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

- បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំលើសំណើសុំ៖

• ផ្តល់អនុលោមភាពផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០២០-២០២៤) អាណត្តិទី៣របស់ក្រុមប្រឹក្សាខេត្តព្រះវិហារ កែប កណ្តាល ព្រះសីហនុ និងខេត្តប៉ៃលិន

• ផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍឆ្នាំ២០២០ចំនួន ២៨គម្រោង រួមមាន៖ ខេត្តត្បូងឃ្មុំ(២គម្រោង) ខេត្តព្រះវិហារ(៧គម្រោង) ខេត្តព្រះសីហនុ(១២គម្រោង) ខេត្តកំពត(៤គម្រោង) និងខេត្តកំពង់ចាម(៣គម្រោង) មានទឹកប្រាក់សរុបចំនួន ៦៦.៧៤១.៥៥០.០០០រៀល (ហុកសិបប្រាំមួយប៊ីលានប្រាំពីររយសែសិបមួយលានប្រាំរយហាសិបពាន់រៀលគត់)។

-បន្តចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងអភិវឌ្ឍបញ្ចប់ឆ្នាំ២០១៩ របស់រដ្ឋបាលរាជធានី ខណ្ឌនិងខេត្ត។

**-រដ្ឋបាលខេត្តស្ទឹងត្រែង** ករណីស្នើសុំគោលការណ៍ដោះដូរដីរបស់រដ្ឋបាលខេត្តស្ទឹងត្រែងទំហំ ៥៩,៤៤ហិកតា ស្ថិតនៅភូមិគីឡូ៨ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ជាមួយដីភាគីឯកជនចំនួន ២០០ឡូតិ៍ ដែលក្នុងមួយឡូតិ៍ទំហំ ៥ម៉ែត្រ x ២០ម៉ែត្រ ស្ថិតនៅភូមិរាជានុកុល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

-រដ្ឋបាលខេត្តកណ្តាល ករណីស្នើសុំអនុញ្ញាតជាគោលការណ៍ជួលអចិន្ត្រៃយ៍រយៈពេល ៥០ឆ្នាំ និងវិនិយោគអភិវឌ្ឍន៍លើដីទំហំ ១.៥០០ហិកតា ស្ថិតនៅក្នុងតំបន់បឹងវាលសំណាប ស្រុកខ្សាច់កណ្តាល និងស្រុកល្វាឯម ខេត្តកណ្តាល។

-រដ្ឋបាលរាជធានីភ្នំពេញ ករណីសំណើសុំដោះដូរដីទំហំ ០៣ហិកតា ស្ថិតនៅខាងកើតវិមានឈ្នះ-ឈ្នះ, ដីទំហំ ០២ហិកតា ស្ថិតនៅតំបន់ទីក្រុងរណប ហ្គាឌីនស៊ីធីព្រែកព្នៅ ខណ្ឌព្រែកព្នៅ និងដីអតីតទីលានចាក់សំរាមស្ទឹងមានជ័យ ទំហំ ៤,៨ហិកតា ស្ថិតនៅខណ្ឌមានជ័យ ជាមួយផ្ទៃបឹងតាមោកទំហំ ៣៤ហិកតា ស្ថិតនៅសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

-រដ្ឋបាលខេត្តកែប ករណីសំណើសុំផ្ទេរការចុះបញ្ជីដីផ្ទះមុខងារត្រៀម ពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តកែប ទៅចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងមុខងារសាធារណៈ។

-រដ្ឋបាលខេត្តកំពង់ចាមករណីរាជរដ្ឋាភិបាលឯកភាពជាគោលការណ៍លើករណីសំណើសុំជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលសង្កាត់កំពង់ចាម(អតីតសាលាឃុំកំពង់ចាម)ក្រុងកំពង់ចាមខេត្តកំពង់ចាម

-រដ្ឋបាលខេត្តបាត់ដំបង ករណីសំណើសុំស្ថាបនាសំណង់ទំនប់បង្វៀរស្ទឹងមង្គលបុរី(ស្ទឹងម្ចាស់កាល) ប្រសព្វនឹងស្ទឹងកំរៀងចំនួន ០១កន្លែង មានមុខកាត់ទទឹងស្ទឹង ២៤ម៉ែត្រ និងកម្ពស់ ១០ម ស្ថិតនៅក្នុងឃុំអូរដា និងឃុំតាក្រីស្រុកកំរៀង ខេត្តបាត់ដំបង។

**៦.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ**

**៦.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**

-បន្តលើកយោបល់អំពីការសុំចុះឈ្មោះ សុំបើកទីស្នាក់ការសាខា សុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មីនៃចេនាសម្ព័ន្ធ សុំប្តូរទីស្នាក់ការកណ្តាល សុំប្តូរឈ្មោះ សុំធ្វើវិសោធនកម្មលក្ខន្តិកៈ សុំលុបឈ្មោះ ការផ្អាកសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំណើផ្សេងៗដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច

-បន្តលើកយោបល់អំពីការសុំតម្កល់សំណុំឯកសារ អំពីការផ្លាស់ប្តូរសមាសភាពចេនាសម្ព័ន្ធ និងការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិច

-បន្តគាំទ្រកិច្ចដំណើរការរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តធ្វើបច្ចុប្បន្នភាព និងបូកសរុបនូវរបាយការណ៍សកម្មភាព និងការផ្តល់លេខគណនីរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តតាមដាន ប្រមូលព័ត៌មានពីគ្រប់បណ្តាញព័ត៌មានសង្គមពាក់ព័ន្ធនឹងការធ្វើសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តតាមដាន ត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខន្តិកៈរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តចូលរួមកិច្ចប្រជុំជាមួយក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ICRP-JG) នៃក្រុមការងារហិរញ្ញវត្ថុ (FATF)

-បន្តចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៩-២០២៣

-ត្រៀមរៀបចំកិច្ចប្រជុំ ក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលដោះស្រាយសំណើនិងសំណូមពររបស់អង្គការសង្គស៊ីវិល ដើម្បីពិនិត្យនិងសិក្សានូវខ្លឹមសារសំខាន់ៗដែលតំណាងអង្គការសង្គមស៊ីវិលស្នើសុំធ្វើវិសោធ-នកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**៦.៤.២-ការងារគណបក្សនយោបាយ**

-បន្តពិនិត្យ លើកយោបល់ អំពីការសុំបង្កើត ឬការសុំចុះបញ្ជី និងសំណើនានា របស់គណបក្សនយោបាយដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច

-បន្តត្រួតពិនិត្យ និងតាមដានគណបក្សនយោបាយ ដើម្បីពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខន្តិកៈរបស់គណបក្សនយោបាយ

-បន្តពិនិត្យ លើកយោបល់ នូវរាល់សំណើពាក់ព័ន្ធនិងការផ្លាស់ប្តូរ ឬការកែប្រែប្រួលនានារបស់គណបក្សនយោបាយ

-បន្តតាមដានពិនិត្យបូកសរុប ប្រមូលព័ត៌មាន ពីគ្រប់បណ្តាញព័ត៌មានសង្គម និងរបាយការណ៍របស់រដ្ឋបាលរាជធានី ខេត្ត ចំពោះគណបក្សនយោបាយ ដែលបានធ្វើសកម្មភាពផ្ទុយពីលក្ខន្តិកៈ ច្បាប់ស្តីពីគណបក្សនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននានា

-រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះគណបក្សនយោបាយ ដែលបានបង្កើត បានចុះបញ្ជី និងត្រូវបានលុបឈ្មោះ

-បន្តបែងចែក ដើម្បីផ្សព្វផ្សាយសៀវភៅច្បាប់ស្តីពីគណបក្សនយោបាយ ជូនក្រសួងមហាផ្ទៃ ក្រសួងស្ថាប័ននានា និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-ត្រៀមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការកំណត់អាករសម្រាប់ការចុះបញ្ជីគណបក្សនយោបាយ៕

**អគ្គនាយក**

ប្រាក់ សំអឿន

<u>ចម្លងជូន៖</u>

-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
(ជូនជ្រាបជាសេចក្តីរាយការណ៍)
-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-អគ្គនាយកដ្ឋានរតនាគារ និងហិរញ្ញវត្ថុ
-អគ្គាធិការដ្ឋាន
-អគ្គនាយកដ្ឋានពន្ធនាគារ
-គ្រប់នាយកដ្ឋានចំណុះអ.រ.ប
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ